ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# របាយការណ៍ជាតិលើកទី៥
# ស្តីពីការអនុវត្តកតិកាសញ្ញាអន្តរជាតិ
# ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
# អនុលោមតាមមាត្រា ៤០ នៃកតិកាសញ្ញាអន្តរជាតិ

ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩

# មាតិកា

ទំព័រ

**I. សេចក្តីផ្តើម** ....................................................... ១

**II. ការឆ្លើយតបទៅនឹងអនុសាសន៍** ....................................................... ៣

ក.វិស័យយុត្តិធម៌....................................................... ៣

ខ.ការងារសិទ្ធិមនុស្ស ....................................................... ១២

គ.សមភាពយេនឌ័រ ការរើសអើងផ្អែកលើភេទ និងអំពើហិង្សាលើស្ត្រី....................................................... ១៣

ឃ.សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ ....................................................... ១៧

ង.អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ....................................................... ២៨

ច.សិទ្ធិបោះឆ្នោតរបស់ជនជាប់ឃុំ....................................................... ២៨

ឆ.សិទ្ធិជនជាតិដើមភាគតិច និងដីធ្លី ....................................................... ៣០

**III.បញ្ហាប្រឈម**....................................................... ៣៣

**IV.យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល**....................................................... ៣៤

**ឯកសារយោង**

## ផ្នែកទី១

## I. សេចក្តីផ្តើម

១. ព្រះរាជាណាចក្រកម្ពុជា មានប្រជាជនប្រមាណ ១៥ ៧១៧ ៦៧៤នាក់[1] គិតត្រឹមឆ្នាំ២០១៧ មានផ្ទៃដី សរុប ១៨១ ០៣៥ គម² ក្នុងនោះមានរាជធានី ១ ខេត្ត ២៤ ក្រុង ២៦ ខណ្ឌ ១២ ស្រុក ១៥៩ ឃុំ ១ ៤១០ សង្កាត់ចំនួន ២៣៦ និងភូមិ ១៤ ៣៨៣។[2]

២. ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសកំពុងមានការអភិវឌ្ឍ ដែលមានកំណើនសេដ្ឋកិច្ចជាមធ្យម៧% ក្នុងរយៈពេលជាង២ទសវត្សរ៍ ហើយបានកើនឡើងក្នុងរង្វង់៧,១%ក្នុងឆ្នាំ២០១៧ និងអាចរក្សាបន្តកំណើននេះនៅឆ្នាំបន្តបន្ទាប់ទៀតផងដែរ។ ផលទុនសរុបប្រចាំឆ្នាំ២០១៦ មាន ២០,០២ប៊ីលានដុល្លារអាមេរិក ដែលប្រជាពលរដ្ឋម្នាក់ជាមធ្យមរកចំណូលបាន ១ ៤៣៥ ដុល្លារអាមេរិក។[3] កត្តាទាំងនេះ បានធ្វើឱ្យប្រទេសកម្ពុជាកំពុងអភិវឌ្ឍពីប្រទេស ដែលមានប្រាក់ចំណូលទាបមកជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ធ្វើឱ្យអត្រាភាពក្រីក្រធ្លាក់ចុះពី ៥៣,២% ក្នុងឆ្នាំ២០០៤ មកត្រឹម ១៣,៥% ក្នុងឆ្នាំ២០១៤។[4]

៣. ព្រះរាជាណាចក្រកម្ពុជា បានទទួលយកគោលការណ៍សិទ្ធិមនុស្សអន្តរជាតិធ្វើជាមូលដ្ឋានគ្រឹះមួយ នៃការរស់នៅដោយសន្តិភាពរបស់ប្រជាពលរដ្ឋ ដូចបានចែងនៅក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាថា "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ (អ.ស.ប.) សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារីនិងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពនិងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀតឡើយ។ ការប្រើប្រាស់សិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់"។

៤. មាត្រា៥១ ថ្មី នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ចែងថា "ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើប្រាស់អំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។ អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ"។

៥. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ បានប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ តម្លាភាព និងគ្មានអំពើហិង្សា។ គណបក្សនយោបាយចំនួន ២០បាន

---

[1] Population Projection of Cambodia 2013-2023 របស់ក្រសួងផែនការ

[2] របាយការណ៍ស្តីពីលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨របស់ក្រសួងមហាផ្ទៃ

[3] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨

[4] របាយការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១៧

ចូលរួមប្រកួតក្នុងការបោះឆ្នោតនេះ ហើយមានអ្នកចេញទៅបោះឆ្នោតចំនួន ៨៣,០២ % ដើម្បីសម្តែងនូវបំណងប្រាថ្នារបស់ខ្លួន ចង់ឃើញនូវការបន្តមាគ៌ាសន្តិភាព ស្ថិរភាព ប្រជាធិបតេយ្យ និងនីតិរដ្ឋ។[5]

**៦.** តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីឆ្នាំ១៩៩៣មក ព្រះរាជាណាចក្រកម្ពុជាអនុវត្តតាមបែបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស លើកកម្ពស់សិទ្ធិសេរីភាព ជំនឿសាសនារបស់ប្រជាពលរដ្ឋ និងអនុវត្តសេដ្ឋកិច្ចទីផ្សារសេរី។[6]

**៧.** ព្រះរាជាណាចក្រកម្ពុជា បានទទួលយក និងផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចំនួនប្រាំបីក្នុងចំណោមសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សសំខាន់ៗទាំងប្រាំបួន មានជាអាទិ៍៖

- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (២៨ វិច្ឆិកា ១៩៨៣)
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (២៦ ឧសភា ១៩៩២)
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (២៦ ឧសភា ១៩៩២)
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (១៥ តុលា ១៩៩២)
- អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (១៥ តុលា ១៩៩២)
- អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៥ តុលា ១៩៩២)
- អនុសញ្ញាស្តីពីសិទ្ធិជនពិការ (២០ ធ្នូ ២០១២)
- អនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ (២៧ មិថុនា ២០១៣)។[7]

**៨.** អនុលោមតាមមាត្រា៤០នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើរបាយការណ៍ជូនទៅគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ ព្រះរាជាណាចក្រកម្ពុជា បានដាក់ជូនអង្គការសហប្រជាជាតិនូវរបាយការណ៍លើកដំបូងកាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៨ ហើយត្រូវបានគណៈកម្មាធិការត្រួតពិនិត្យនាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៩។ របាយការណ៍ផ្តួបលើកទី២ ទី៣ និងទី៤ បានដាក់ជូនអង្គការសហប្រជាជាតិកាលពីខែកញ្ញា ឆ្នាំ២០១២ និងបានត្រូវពិនិត្យនាសម័យប្រជុំលើកទី ៣១៥៧ (CCPR/C/SR.3157) ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥។ របាយការណ៍ដែលដាក់ជូននាពេលនេះ គឺឆ្លើយតបទៅនឹងសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយ ដែលកម្ពុជាទទួលបានកាលពីសម័យប្រជុំលើកទី ៣១៥៧ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥។

---

[5] សេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០១៨

6 ទីស្តីការគណរដ្ឋមន្ត្រី របាយការណ៍ស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១២ -២០១៦ ខែមេសា ឆ្នាំ ២០១៧

7 រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ ស្តីពីការត្រួតពិនិត្យឡើងវិញតាមកាលកំណត់ជាសកល ជុំទី៣ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ខែតុលា ឆ្នាំ ២០១៨

## ផ្នែកទី២

## II. ការឆ្លើយតបទៅនឹងអនុសាសន៍

### ក. វិស័យយុត្តិធម៌(អនុសាសន៍លេខ៥ ១១ ១៤ ១៥ ១៧ ២០ ២៣ ២៤ និង២៥)

### អនុសាសន៍លេខ៥

៩. នៅព្រះរាជាណាចក្រកម្ពុជា មានសាលាសម្រាប់ធ្វើការបណ្តុះបណ្តាលចៅក្រម និងមេធាវីដែលក្នុងកម្មវិធីបណ្តុះបណ្តាលនៃសាលាទាំងពីរនេះ បានដាក់បញ្ចូលនូវមេរៀនស្តីពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាពិសេសកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ។

១០. វិទ្យាស្ថានរ៉ាអ៊ូលវ៉ុលឡឺប៊ែក ដែលជាអង្គការមិនមែនរដ្ឋាភិបាល ក្រោមការឧបត្ថម្ភគាំទ្រពីប្រទេសស៊ុយអ៊ែត បានជួយបណ្តុះបណ្តាលគ្រូបង្គោលជំនាញច្បាប់សិទ្ធិមនុស្សអន្តរជាតិ ចំនួន៨រូបសម្រាប់បង្រៀនច្បាប់អន្តរជាតិនេះ ដល់សិស្សចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងដល់សិស្សមេធាវី នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី។

១១. រហូតមកដល់ត្រឹមឆ្នាំ២០១៨ ព្រះរាជាណាចក្រកម្ពុជា បានបណ្តុះបណ្តាលសិស្សចៅក្រម បានចំនួន៨វគ្គ ដែលក្នុងមួយវគ្គៗមានចំនួន៥៥នាក់។ ដូច្នេះចៅក្រមសរុបមាន៤៤០នាក់បានទទួលការបណ្តុះបណ្តាលអំពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ដោយឡែកចំពោះចំនួនមេធាវី បច្ចុប្បន្ននេះ មានចំនួនប្រមាណជាង៨០០នាក់ដែលបានទទួលការបណ្តុះបណ្តាលអំពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

១២. នៅព្រះរាជាណាចក្រកម្ពុជា អានុភាពនៃសិទ្ធិទាំងឡាយ ដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិ ដែលជាមូលដ្ឋាននៃការចេញសេចក្តីសម្រេចរបស់តុលាការ ដូចមាត្រា១២៨ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា បានចែងថា ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធី និងច្បាប់ជាធរមាន។

### អនុសាសន៍លេខ១១

១៣. នៅព្រះរាជាណាចក្រកម្ពុជា គ្រប់អំពើរំលោភបំពានច្បាប់រួមទាំងករណីរំលោភសិទ្ធិមនុស្ស ផងដែរ ត្រូវបានធ្វើការស៊ើបអង្កេតដោយអង្គភាពមានសមត្ថកិច្ច ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដែលសមត្ថកិច្ចនេះត្រូវបានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាអាទិ៍ៈ

- **-មាត្រា៥៦.២** នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។
- **-មាត្រា៧៤.១** មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបណ្តឹងនោះត្រូវតែចាប់ផ្តើមភ្លាមៗធ្វើការស៊ើបអង្កេត ឬក៏បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹងនេះ ទៅព្រះរាជអាជ្ញាដើម្បីចាត់ការតទៅ។

**-មាត្រា៧៥.១** ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចតម្កល់រឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានទេ ទោះបីជាក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬ ក៏មានការដកពាក្យបណ្ដឹងក៏ដោយ។

**១៤.** អនុលោមតាមគោលការណ៍ច្បាប់ នៅពេលមានបទល្មើសកើតឡើងមិនចំពោះតែលើអ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស តួអង្គសង្គមស៊ីវិលផ្សេងៗទៀតនោះឡើយ ទោះបីកើតលើប្រជាពលរដ្ឋធម្មតា ក៏អាជ្ញាធរមានសមត្ថកិច្ចជាពិសេសនគរបាលយុត្តិធម៌ ត្រូវធ្វើការស៊ើបអង្កេតភ្លាមទៅតាមមុខងារដូចបានកំណត់ក្នុងបញ្ញត្តិច្បាប់ខាងលើ។ ទោះបីយ៉ាងនេះក៏ដោយ ក៏ការស៊ើបអង្កេតមិនមែនបានផលវិជ្ជមានទាំងស្រុងលើគ្រប់ករណីដោយភ្លាមៗនោះទេ ដែលករណីខ្លះ ត្រូវអូសបន្លាយពេលវេលាយូរដោយភាពស្មុគស្មាញបទល្មើស ហើយករណីខ្លះទៀតពិបាកក្នុងការស្វែងរកចាប់ខ្លួនជនល្មើសជាដើម។ តែទោះជាយ៉ាងណាក៏ដោយ ក៏អាជ្ញាធរមានសមត្ថកិច្ច មិនទុកករណីបែបនេះចោលនោះឡើយ គឺនៅតែចាត់វិធានការទៅតាមនីតិវិធីច្បាប់ តួយ៉ាងដូចជាករណីខាងក្រោម៖

-កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ នៅភូមិក្បាលកន្លង់ ឃុំពាមឆ្កោក ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង មានជនសង្ស័យ០៦នាក់ បាននាំគ្នាវាយទៅលើឈ្មោះ សួន ចាន់ អ្នកយកព័ត៌មានរបស់កាសែត "មាគ៌ាកម្ពុជា" ដែលត្រូវបានស្លាប់នៅឯមន្ទីរពេទ្យ។ ជនសង្ស័យទាំង០៦នាក់ បានរត់គេចខ្លួនបាត់ ប៉ុន្តែត្រូវបានចោទប្រកាន់ពីបទឃាតកម្ម ហើយត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារក្នុងម្នាក់ៗ១៣ឆ្នាំ និងឱ្យម្នាក់ៗសងជំងឺចិត្តចំនួន៥.០០០.០០០ (ប្រាំលាន) រៀល ទៅគ្រួសារជនរងគ្រោះ តាមសាលក្រមលេខ២៧យ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់តុលាការខេត្តកំពង់ឆ្នាំង។

១៥. កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ នៅភូមិឃ្សឹមក្រៅ ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ មានឃាតកម្មលើរូបអ្នកកាសែតខ្មែរប្រជាធិបតេយ្យមានឈ្មោះ **តាំង ទ្រី**។ តុលាការបានផ្តន្ទាទោសជនជាប់ចោទឈ្មោះ ឡា ណារ៉ុង ជាប់ពន្ធនាគារចំនួន ៧ឆ្នាំ ជាទោសត្រួតពីបទឃាតកម្ម និងប្រើប្រាស់អាវុធគ្មានលិខិតអនុញ្ញាត និងឱ្យសងជំងឺចិត្តចំនួន១០.០០០.០០) ដប់លាន( រៀល) ទៅគ្រួសារជនរងគ្រោះ តាមសាលក្រមលេខ ១៤យ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ របស់តុលាការខេត្តក្រចេះ។

កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ នៅភូមិជួយអំពិល ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគីរី មានឃាតកម្មលើរូបអ្នកកាសែតវះជនខ្មែរ ដែលមានឈ្មោះ **ហង្ស សេរីឧត្តម**។ តុលាការ បានសម្រេចឱ្យឈ្មោះ អ៊ាន ប៊ុនហេង និងឈ្មោះ ស៊ឺ ស្រីវី រួចផុតពីការចោទប្រកាន់ពីបទឃាតកម្មគិតទុកជាមុនតាមអំណាចសាលក្រមលេខ ២៥(ខ) ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ របស់តុលាការខេត្តរតនគីរី។ នៅសាលាឧទ្ធរណ៍តាមរយៈសាលដីកាលេខ ៥៦ក្រ VII/ធ២១-១១-២០១៤ បានសម្រេចតម្កល់សាល

ក្រមព្រហ្មទណ្ឌរបស់តុលាការខេត្តរតនគីរីទុកជាបានការ ដដែលដោយសំអាងថាគ្មានភស្តុតាង ពិរុទ្ធភាពលើអ្នកទាំងពីរខាងលើ។

**អនុសាសន៍លេខ ១៤**

១៦. លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន និងការផ្តល់សាលក្រមស្តាពរដល់ពន្ធនាគារ ត្រូវបានកំណត់ជាក់លាក់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដូចជា៖

-មាត្រា២០៣៖ ជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព ។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងផ្នែកនេះ។

-មាត្រា២០៤៖ ការឃុំខ្លួនបណ្តោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១(មួយ)ឆ្នាំ។

-មាត្រា២០៥៖ ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់កាលណាការឃុំខ្លួនបណ្តោះអាសន្ន នេះអាចជាការចាំបាច់៖

១. ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី។

២. ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬ ដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។

៣. ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ។

៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥. ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។

៦. ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។

**អនុសាសន៍លេខ ១៥**

**១៧.** បន្ថែមពីលើក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជាបានប្រកាសឱ្យប្រើ "ច្បាប់ស្តីពីយុត្តិធម៌អនីតិជន" កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦។ ច្បាប់នេះមានគោលបំណងធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស គាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍។ ជាមួយគ្នានេះ ច្បាប់នេះក៏មានគោលដៅកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឱ្យបានច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ដែលប្រព្រឹត្តដោយអនីតិជន។ វិធាននៃច្បាប់នេះបង្កើតឱ្យមានប្រព័ន្ធយុត្តិធម៌អនីតិជន ដែលត្រូវប្រតិបត្តិ និងអនុវត្តនៅក្នុងសាលាជម្រះក្តីគ្រប់លំដាប់ថ្នាក់។

**១៨.** បច្ចុប្បន្ននេះ នៅព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានប្រព័ន្ធយុត្តិធម៌អនីតិជនដាច់ដោយឡែក នោះទេ គឺមានតែការអនុវត្តនីតិវិធីយុត្តិធម៌អនីតិជននៅក្នុងតុលាការព្រហ្មទណ្ឌ ដោយឱ្យមានចៅក្រម ជំនាញផ្នែកអនីតិជនជាអ្នកមានសមត្ថកិច្ចចាត់ការរឿងក្ដីអនីតិជនទៅតាមនីតិវិធី ដែលបានកំណត់ក្នុង លក្ខណៈកុមារមេត្រី។ ប៉ុន្តែតាមគោលការណ៍ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ បានអនុញ្ញាតឱ្យ បង្កើតតុលាការជំនាញតាមការចាំបាច់ក្រៅពីតុលាការជំនាញទាំងបួន រួមមានតុលាការព្រហ្មទណ្ឌ តុលាការរដ្ឋប្បវេណី តុលាការការងារ និងតុលាការពាណិជ្ជកម្ម។ ដូច្នេះព្រះរាជាណាចក្រកម្ពុជា អាច នឹងបង្កើតតុលាការកុមារក្នុងពេលចាំបាច់ណាមួយ។

**១៩.** បច្ចុប្បន្នថ្វីត្បិតតែច្បាប់ ស្ដីពីយុត្តិធម៌អនីតិជន ត្រូវបានប្រកាសឱ្យប្រើប្រាស់កាលពីខែកក្កដា ឆ្នាំ ២០១៦ តែជនជាប់ឃុំជាអនីតិជនកំពុងស្ថិតក្រោមការគ្រប់គ្រង របស់អគ្គនាយកដ្ឋានពន្ធនាគារនៅ ឡើយ ដោយហេតុថា លិខិតបទដ្ឋាន និងនីតិវិធី ស្ដីពីការគ្រប់គ្រងជនជាប់ឃុំជាអនីតិជននៅកំពុងស្ថិត ក្នុងដំណាក់កាលធ្វើសេចក្ដីព្រាងនៅឡើយ។ ក្រោមកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ UNICEF រាជរដ្ឋា ភិបាលបានបន្តកែទម្រង់ប្រព័ន្ធយុត្តិធម៌សម្រាប់អនុវត្តចំពោះជនល្មើសជាអនីតិជនជាអាទិ៍ ចាប់តាំងពី ដំណាក់កាលឃាត់ខ្លួន បញ្ជូនខ្លួនទៅតុលាការ បញ្ជូនទៅឃុំនៅពន្ធនាគារ កម្មវិធីអប់រំកែប្រែស្ដារនីតិ សម្បទា រហូតធ្វើសមាហរណកម្ម។ ចំពោះការគ្រប់គ្រងជនជាប់ឃុំជាអនីតិជន មកទល់ពេលនេះពួកគេ ត្រូវបានឃុំដោយឡែកតាមអគារបែងចែកដោយភេទ អាយុ និងចំណាត់ថ្នាក់សន្តិសុខ ដោយពុំបាន ដាក់ឡុកឡំជាមួយនីតិជននោះឡើយ។

**២០.** ចំពោះកំណែទម្រង់ប្រព័ន្ធយុត្តិធម៌សម្រាប់អនីតិជន រាជរដ្ឋាភិបាល បានបង្កើតក្រុមការងារអន្តរ ក្រសួង ដែលមានសមាសភាពមកពីក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សាលាឧទ្ធរណ៍ និងមានរដ្ឋលេខាធិការក្រសួងយុត្តិធម៌ជាប្រធាន។ ក្រោមភាពជាដៃគូ សហការជាមួយ UNICEF គណៈកម្មាធិការអន្តរក្រសួងកំពុងសិក្សាពីលទ្ធភាពក្នុងការជំរុញការអនុវត្ត ទោសជំនួសសម្រាប់បទល្មើសស្រាលៗ ប្រព្រឹត្តដោយអនីតិជន និងបានតាក់តែងផែនការ វិធានការ និង លិខិតបទដ្ឋានពាក់ព័ន្ធនានា ដើម្បីផ្ទេរការគ្រប់គ្រងជនជាប់ឃុំជាអនីតិជន ពីក្រសួងមហាផ្ទៃ ទៅក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់គ្រងតាមច្បាប់ស្ដីពីយុត្តិធម៌អនីតិជនវិញ។[៥]

**២១.** នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរយៈពេល ៣ឆ្នាំ (២០១៨ ដល់២០២០)នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។ចំណុចគន្លឹះ នៃផែនការយុទ្ធសាស្ត្រ

[៥] របាយការណ៍ក្រសួងមហាផ្ទៃលេខ ២១៥១សជណចុះថ្ងៃទី១២ ធ្នូ ឆ្នាំ ២០១៨

និងផែនការប្រតិបត្តិ ផ្តោតជាសំខាន់ទៅលើការធ្វើឱ្យមានការយល់ដឹងពីផលប្រយោជន៍នៃការអនុវត្តនូវវិធានការបង្វែរ និងវិធានការផ្សេងក្រៅពីការឃុំខ្លួន ដែលអាចកាត់បន្ថយការប្រព្រឹត្តបទល្មើសសាជាថ្មី និងការកាត់បន្ថយចំនួនអនីតិជនជាប់ឃុំ ហើយក៏អាចឈានដល់ការកាត់បន្ថយបន្ទុកចំណាយរបស់រដ្ឋក្នុងការគាំទ្រទៅលើការងារឃុំឃាំងផងដែរ។

**អនុសាសន៍លេខ ១៧**

**២២**. ជាគោលការណ៍ ជនជាប់ចោទត្រូវតែមានសេរីភាព ហើយការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើបានតែក្នុងករណីពិសេសដែលជាជម្រើសចុងក្រោយ ដោយផ្អែកលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ នៅព្រះរាជាណាចក្រកម្ពុជា ជនល្មើសមានសិទ្ធិទទួលបានមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬ តាមការចាត់តាំងនៅគ្រប់ដំណាក់កាលនៃនីតិវិធី ដែលលក្ខខណ្ឌនេះត្រូវបានកំណត់ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាអាទិ៍។

**២៣**. មាត្រា៩៧ កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ប្រាប់ដល់សាមីខ្លួនឱ្យដឹងផងដែរ អំពីសិទ្ធិដែលបានចែងក្នុងមាត្រា៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ។ ហើយមាត្រា៩៨ បានកំណត់ថា ក្នុងរយៈពេល២៤ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលត្រូវឃាត់ខ្លួន អាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ។

**២៤**. នៅដំណាក់កាលចៅក្រមស៊ើបសួរយោងលើមាត្រា១៤៣កថាខណ្ឌទី៣ និងទី៤ចែងថា ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទ ឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បន្ថែមលើនេះ មាត្រា ១៤៥ ចែងថា កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត៥ថ្ងៃ មុនការសួរចម្លើយ។

**២៥**. មាត្រា៣០១ កំណត់ថា ជំនួយមេធាវីត្រូវតែមានជាច់ខាតនៅក្នុងករណីដូចតទៅៈ

១-ករណីបទឧក្រិដ្ឋ។

២-កាលណាជនជាប់ចោទជាអនីតិជន។ បើគ្មានការជ្រើសរើសដោយជនជាប់ចោទទេ មេធាវីត្រូវបានចាត់តាំងតាមគំនិតរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ទន្ទឹមនេះ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា៦ ចែងថា អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី ដែលក្នុងនេះអនីតិជនត្រូវទទួលបានមេធាវី បន្ទាប់ពីត្រូវបាននាំខ្លួនមកដល់អង្គភាពនគរបាល (មាត្រា១៨)។

២៦. ដើម្បីផ្តល់ភាពងាយស្រួល ក្នុងការប្រើប្រាស់ អនុវត្តសិទ្ធិទទួលបានមេធាវីរបស់ជន ដែលត្រូវបានឃាត់ខ្លួន ឬត្រូវបានចោទប្រកាន់ ក្រសួងយុត្តិធម៌ដោយមានការគាំទ្រពីសហគមន៍អ៊ឺរ៉ុបបានរៀបចំគោលនយោបាយស្តីពីជំនួយផ្នែកច្បាប់ ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ឱ្យមានប្រសិទ្ធភាព។ សេចក្តីព្រាងគោលនយោបាយជំនួយផ្នែកច្បាប់នេះ បាននិងកំពុងដាក់ឱ្យពិភាក្សាជាមួយអ្នកពាក់ព័ន្ធ។ ទន្ទឹមនេះ ដើម្បីលើកកម្ពស់សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ របស់បុគ្គលដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ បានសហការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បង្កើតឱ្យមានប្រតិភូគណៈមេធាវីប្រចាំការនៅតាមគ្រប់សាលាដំបូងរាជធានី ខេត្ត។ ថ្មីៗនេះសម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបង្កើតឱ្យមានយន្តការក្រុមមេធាវីមួយសម្រាប់ជួយការពារផ្លូវច្បាប់ដល់ស្ត្រីក្រីក្រ ជាពិសេសស្ត្រីងាយរងគ្រោះដោយមិនយកកម្រៃ ដើម្បីជានាយុត្តិធម៌សង្គម និងនីតិរដ្ឋ។

**២៧.** ដើម្បីលើកស្ទួយសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ថវិកាចំនួន៩០០លានរៀល ក្នុង ឆ្នាំ២០១៨ ហើយបានកើនឡើងដល់ចំនួន ១ ២០០ លានរៀល ក្នុងឆ្នាំ២០១៩ សម្រាប់ជួយដល់ដំណើរការការពារក្តីជូនជនក្រីក្រ ដែលគណៈមេធាវីបានរៀបចំឱ្យមានមេធាវីសម្រាប់ការពារក្តីឱ្យជនក្រីក្រដោយមិនយកកម្រៃ។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានទទួលថវិកាចំនួន ៥០០លានរៀលក្នុងមួយឆ្នាំៗសម្រាប់ជួយការពារផ្លូវច្បាប់ដល់ស្ត្រីរងគ្រោះពីការរំលោភបំពានផ្សេងៗ។

**អនុសាសន៍លេខ២០**

២៨. ឯករាជ្យភាពរបស់តុលាការត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ដែលកំណត់ជាអាទិ៍៖

- **មាត្រា ១២៨ថ្មី** អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការ ធានារក្សាអនាគត និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។
- **មាត្រា ១៣០ថ្មី** គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ។
- **មាត្រា ១៣២ថ្មី** ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។

២៩. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ត្រូវបានរៀបចំឡើងដោយគិតគូរគ្រប់ជ្រុងជ្រោយអំពីគោលការណ៍គ្រឹះទាំងឡាយ ដើម្បីធានានូវឯករាជ្យនៃអំណាចតុលាការ ស្របតាមបទដ្ឋានអន្តរជាតិ ដែលយោងតាមបញ្ញត្តិច្បាប់នេះ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី ដោយឯករាជ្យ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។

៣០. ដើម្បីគាំទ្រដល់កិច្ចដំណើរការរបស់អង្គការតុលាការ និងអង្គការអយ្យការ បញ្ញត្តិនៃច្បាប់នេះបានបង្កើតឱ្យមានអង្គភាពរដ្ឋបាល ធ្វើជាសេនាធិការលើការងារបុគ្គលិករដ្ឋបាល និងហិរញ្ញវត្ថុ របស់អង្គការតុលាការ និងអង្គការអយ្យការ គឺក្រសួងយុត្តិធម៌ និងអង្គភាពរដ្ឋបាល ពុំមានអំណាចជ្រៀតជ្រែកកិច្ចការ និងជះឥទ្ធិពលលើសិទ្ធិជម្រះក្តីរបស់តុលាការបានឡើយ។ ផ្ទុយទៅវិញអង្គភាពរដ្ឋបាលនេះ គឺជាជំនួយរបស់អង្គការតុលាការ និងអង្គការអយ្យការ ដើម្បីធានាឱ្យមានកិច្ចដំណើរការល្អរបស់អង្គការទាំងពីរនេះតែប៉ុណ្ណោះ ដែលមិនប៉ះពាល់ដល់អំណាចឯករាជ្យរបស់តុលាការឡើយ។

**អនុសាសន៍លេខ ២៣**

៣១. នៅព្រះរាជាណាចក្រកម្ពុជា ពុំមានបទប្បញ្ញត្តិ ដែលរើសអើងឈរលើហេតុផល ភេទ អាយុ និង ប្រាក់ចំណូល ទាក់ទងទៅនឹងអាពាហ៍ពិពាហ៍នេះឡើយ។ វិធានការផ្លូវច្បាប់ក៏ដូចជាវិធានការផ្នែករដ្ឋបាល ដែលបានដាក់ចេញទាក់ទងទៅនឹងអាពាហ៍ពិពាហ៍កន្លងមកនេះ គឺក្នុងគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍ដល់ស្ត្រីកម្ពុជាតែប៉ុណ្ណោះ ពុំមានហេតុផលអ្វីផ្សេងនោះឡើយ។

៣២. មាត្រា ៩៥០នៃក្រមរដ្ឋប្បវេណី ដែលចែងថា នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល១២០(មួយរយម្ភៃ)ថ្ងៃពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល។ បទប្បញ្ញត្តិនេះ មិនមានន័យរឹតត្បិតសិទ្ធិរបស់នារីនោះទេ គឺក្នុងគោលបំណងដើម្បីការពារផលប្រយោជន៍របស់នារី ក៏ដូចជាបុរស ដែលថានឹងរៀបការជាមួយគ្នានោះទៅវិញទេ។ ព្រោះថាក្នុងរយៈពេលនេះ នារីអាចមានផ្ទៃពោះ ដែលបន្សល់ទុកពីអាពាហ៍ពិពាហ៍មុន ដែលករណីនេះ ធ្វើឱ្យមានផលប៉ះពាល់ដល់ការរៀបអាពាហ៍ពិពាហ៍ថ្មី ក្នុងអំឡុងពេល១២០ថ្ងៃនេះ។ ករណីនេះ ប្រសិនបើមានការទទួលស្គាល់ និងយល់ព្រមពីសាមីខ្លួន នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានភ្លាម បន្ទាប់ពីអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល ដូចក្នុងកថាខណ្ឌទី២ នៃមាត្រា៩៥០ នៃក្រមរដ្ឋប្បវេណីនេះចែងថា" បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលនារីមានផ្ទៃពោះនៅមុនពេល ដែលអាពាហ៍ពិពាហ៍មុនត្រូវរំលាយ ឬលុបចោល ហើយបានសម្រាលកូន ឬចំពោះករណី ដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត"។

៣៣. ដោយឡែកចំពោះអនុក្រឹត្យលេខ១៨៣ឆ្នាំ២០០៨ ដែលបានកម្រិតអាយុក្រោម៥០ឆ្នាំ និងមានប្រាក់ចំណូលយ៉ាងតិច ២.៥០០ដុល្លារអាមេរិក ចំពោះបុរសបរទេស ដែលមានបំណងស្នើសុំរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីខ្មែរ គ្រាន់តែជាវិធានការមួយដើម្បីជួយការពារសិទ្ធិ និងផលប្រយោជន៍របស់ស្ត្រីខ្មែរ ដែលនឹងរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសតែប៉ុណ្ណោះ។ ករណីនេះ ជាមេរៀនពិសោធន៍កន្លងមកធ្វើឱ្យស្ត្រីខ្មែរ ដែលរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ប្រភេទនេះត្រូវរងគ្រោះយ៉ាងធ្ងន់ធ្ងរជាអាទិ៍:

ស្ត្រីខ្មែរដែលរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ដែលមានវ័យចំណាស់អាយុលើសពី៥០ឆ្នាំ មួយចំនួនត្រូវបានបុរសបរទេសទាំងនេះ យកទៅធ្វើជាស្ត្រីបម្រើផ្ទាល់ខ្លួនដោយដាច់ថ្លៃ ដែលគេគិតថា ប្រសើរជាងការដែលជួលស្ត្រីផ្សេងមកធ្វើជាអ្នកបម្រើ។ ករណីនេះ ធ្វើឱ្យស្ត្រីខ្មែររងគ្រោះយ៉ាងធ្ងន់ធ្ងរ គឺ បាត់បង់ទាំងសិទ្ធិសេរីភាព និងផលប្រយោជន៍គ្រប់បែបយ៉ាង។

ស្ត្រីខ្មែរដែលរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ដែលមានប្រាក់ចំណូលទាបមួយចំនួន ក៏ត្រូវបាន គេយកទៅធ្វើជាទាសករនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ឬដាំដំណាំដោយគ្មានបានផលប្រយោជន៍ដល់ ខ្លួនអ្វីសោះឡើយ គឺរស់នៅដូចជាទាសករសុទ្ធសាធ។ ក៏ប៉ុន្តែបច្ចុប្បន្នដោយមានការវិវត្តជាវិជ្ជមាន រាជ រដ្ឋាភិបាលកម្ពុជាបានលើកលែងលក្ខខណ្ឌអាយុចេញចាប់ពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយរក្សា ទុកការកំណត់ប្រាក់ចំណូលរបស់បុរសបរទេសនៅដដែល ដើម្បីរក្សាលំនឹងជីវភាពគ្រួសាររបស់គូស្វាមី ថ្មីនេះ ជាពិសេសក្នុងករណីស្ត្រីខ្មែរទាំងនោះត្រូវទៅរស់នៅជាមួយស្វាមីនៅបរទេស។

**អនុសាសន៍លេខ២៤**

**៣៤.** ការដាក់ទណ្ឌកម្មលើរូបរាងកាយ គឺជាអំពើហិង្សាដោយចេតនា ការបង្កឱ្យមានរបួសដោយ អចេតនា ដែលសុទ្ធតែជាបទល្មើសមានចែងក្នុងក្រមព្រហ្មទណ្ឌ និងទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន ទោះបីប្រព្រឹត្តដោយឪពុកម្តាយ ឬអាណាព្យាបាលក៏ដោយ។ ទោះបីយ៉ាងនេះក៏ដោយ ជាទម្លាប់ដែល បានបន្សល់ទុកពីអតីតកាលកន្លងមក ឪពុកម្តាយ អ្នកអាណាព្យាបាលមួយចំនួន នៅតែយកការដាក់ ទណ្ឌកម្មលើរូបរាងកាយនេះ ធ្វើជាមធ្យោបាយក្នុងការដាក់វិន័យ ដើម្បីអប់រំកូន។

**៣៥.** ដើម្បីទប់ស្កាត់ការដាក់ទណ្ឌកម្មលើរូបរាងកាយចំពោះកូនអំពីសំណាក់ ឪពុកម្តាយ ឬអ្នកអាណា ព្យាបាល រាជរដ្ឋាភិបាល បានដាក់ចេញនូវច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សានៅក្នុងគ្រួសារ ដែលត្រូវ បានប្រកាសឱ្យប្រើកាលពីឆ្នាំ២០០៥។ ច្បាប់នេះ មានគោលបំណងសំខាន់ ដាក់ចេញនូវវិធានការជួយ ដល់ជនរងគ្រោះ និងចាត់វិធានការផ្លូវច្បាប់ចំពោះជន ដែលប្រព្រឹត្តអំពើហិង្សា ទោះជាក្នុងទម្រង់ជាការ ដាក់វិន័យក៏ដោយ បើសិនជាទម្រង់នេះ ស្ថិតក្នុងស្ថានភាព ដែលពុំអាចអត់ឱនឱ្យបាន។

**៣៦.** នៅព្រះរាជាណាចក្រកម្ពុជា ទោះជាឪពុក ម្តាយ ឬអ្នកអាណាព្យាបាលក៏ដោយ ឱ្យតែប្រើការដាក់ ទណ្ឌកម្មលើរូបរាងកាយកូនក្នុងកម្រិតមួយនឹងត្រូវទទួលទោសទៅតាមច្បាប់ ដោយមិនអាចអត់ឱនឱ្យ បាននោះឡើយ។ ជាក់ស្តែងកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ បុរសម្នាក់ អាយុ៣៤ឆ្នាំ នៅភូមិថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ត្រូវបាននគរបាល មានសមត្ថកិច្ច ចាប់ឃាត់ខ្លួន កសាងសំណុំរឿងបញ្ជូនទៅតុលាការ ដោយបុរសនោះបានប្រើទណ្ឌកម្មលើរូបរាងកាយកុមារអាយុ៤ឆ្នាំ ដែលត្រូវជាក្មួយបង្កើតរស់នៅជាមួយ។

៣៧. ព្រមជាមួយនឹងការពង្រឹងការអនុវត្តច្បាប់ រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី បានសហការរៀបចំ "ផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឆ្នាំ២០១៧-២០២១"។ ផែនការសកម្មភាពនេះបានកំណត់អន្តរាគមន៍ជាយុទ្ធសាស្ត្រសំខាន់ៗចំនួន៥ ដើម្បីសម្រេចឱ្យបាននូវគោលដៅក្នុងការបញ្ចប់អំពើហិង្សាលើកុមារ រួមមាន៖ ១).ការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការ ២).ការទប់ស្កាត់បឋម ៣). សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពារកុមារ ៤).ការបង្កើត និងការធ្វើវិសោធនកម្មច្បាប់ និងគោលនយោបាយ និង ៥).ការពិនិត្យតាមដាន និងវាយតម្លៃ។

កន្លងទៅក្រសួងអប់រំ យុវជន និងកីឡា បានពិនិត្យ និងសង្កេតឃើញថា មានបុគ្គលិកអប់រំមួយចំនួនតូចប៉ុណ្ណោះ ដែលបានប្រព្រឹត្តអំពើផ្ទុយទៅនឹងក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តពាក់ព័ន្ធការដាក់ទណ្ឌកម្មលើរូបរាងកាយ និងការប្រើអំពើហិង្សាលើកុមារ។ ក្នុងនោះ មានករណីជាក់ស្តែងមួយចំនួនដូចខាងក្រោម៖

១. ករណីបុគ្គលិកអប់រំ ១ករណី បម្រើការនៅក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ឆ្នាំង ត្រូវបានមាតាបិតាសិស្សដាក់ពាក្យបណ្តឹងពាក់ព័ន្ធនឹងការបៀតបៀនកេរ្តិ៍ខ្មាសសិស្ស។ ចំពោះវិធានការអនុវត្ត ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សដើម្បីរង់ចាំលទ្ធផលស្ថាពរពីស្ថាប័នតុលាការ។

២. ករណីបុគ្គលិកអប់រំ ១ករណី បម្រើការនៅក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ បានដាក់ទណ្ឌកម្មចំពោះសិស្សឆ្លើយខុស ដោយឱ្យឈរ និងវាយស្រាលៗដោយបន្ទាត់ ក្នុងនោះមាតាបិតាសិស្ស បានដាក់ពាក្យបណ្តឹងទាមទារសំណងជំងឺចិត្ត និងការព្យាបាលរបួសស្នាម។ ចំពោះវិធានការអនុវត្តក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចដាក់ឱ្យមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវហៅបុគ្គលិកអប់រំដែលបានប្រព្រឹត្តខុស មកធ្វើការណែនាំ និងស្តីបន្ទោសដោយផ្ទាល់មាត់ ដើម្បីបញ្ឈប់នូវសកម្មភាពខាងលើនេះ។[១]

៣. បុគ្គលិកអប់រំ ១ករណីនៅក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង បានដាក់ទណ្ឌកម្មចំពោះសិស្សដោយឱ្យសិស្សឆ្លើយត្រូវស្រាតខោ ឬស្រាតសំពត់សិស្សឆ្លើយខុសក្នុងនោះមាតាបិតាសិស្ស បានដាក់ពាក្យប្តឹងទាមទារសំណងជំងឺចិត្ត និងការអនុវត្តតាមផ្លូវច្បាប់។ ចំពោះវិធានការអនុវត្ត មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀងបានហៅបុគ្គលិកអប់រំ ដែលបានប្រព្រឹត្តខុសនោះ

[១] ក្រសួងអប់រំ យុវជន និងកីឡាលិខិតលេខ៧៨៣អយក.នក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០១៩

មកធ្វើការណែនាំ និងស្តីបន្ទោសដោយផ្ទាល់មាត់ ដើម្បីបញ្ឈប់នូវសកម្មភាពខាងលើនេះ ព្រមទាំងបានផ្លាស់ប្តូរកន្លែងបម្រើការងារដោយបង្វិលមកបម្រើការនៅការិយាល័យអប់រំ យុវជន និងកីឡាស្រុករំដួលវិញ។

**អនុសាសន៍លេខ ២៥**

៣៨. យោងតាមមាត្រា ៥១ ថ្មី នៃរដ្ឋធម្មនុញ្ញ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។ ដើម្បីឱ្យការរៀបចំតាក់តែងច្បាប់និងលិខិតបទដ្ឋានមានភាពត្រឹមត្រូវ និងមានការចូលរួមតាមបែបប្រជាធិបតេយ្យ រាជរដ្ឋាភិបាល បានដាក់ចេញនូវសារាចរណែនាំស្តីពីនីតិវិធីនៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលត្រូវឱ្យស្ថាប័នរាជរដ្ឋាភិបាលទាំងអស់ ដែលមានមុខងាររៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត អនុវត្តតាម ដែលក្នុងនោះការផ្តល់ឱ្យមានការចូលរួមពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ និងប្រជាពលរដ្ឋគឺជានីតិវិធីជាមូលដ្ឋាន។ ម្យ៉ាងវិញទៀត កិច្ចប្រជុំនៃអង្គនីតិប្បញ្ញត្តិធ្វើឡើងជាសាធារណៈ មានន័យថា សមាជិករដ្ឋសភា និងព្រឹទ្ធសភា ដែលជាតំណាងរបស់រាស្ត្រ មានលទ្ធភាពគ្រប់គ្រាន់បានដឹង និងចូលរួមជជែកដេញដោលលើសេចក្តីព្រាងច្បាប់ទាំងឡាយ។ ជាមួយគ្នានេះ សេចក្តីព្រាងច្បាប់សំខាន់ៗមួយចំនួនក៏បានធ្វើការប្រឹក្សាជាសាធារណៈ មុននឹងដាក់ជូនអង្គនីតិប្បញ្ញត្តិពិនិត្យ និងអនុម័ត។

៣៩. ដើម្បីពង្រឹងការរៀបចំច្បាប់ឱ្យមានការចូលរួម រាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តកម្មវិធីការវាយតម្លៃផលប៉ះពាល់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្រោមជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីធ្វើការសិក្សាវាយតម្លៃពីផលប៉ះពាល់ មុននឹងការចាប់ផ្តើមរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលក្នុងនោះការចូលរួមពិគ្រោះយោបល់ពីអ្នកពាក់ព័ន្ធ ជាពិសេសពីប្រជាពលរដ្ឋជាដំណាក់កាលៗ ដែលទាមទារឱ្យមានការសិក្សាឱ្យបានស៊ីជម្រៅ និងមានភាពច្បាស់លាស់។

ក្រសួងយុត្តិធម៌ក្រោមកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នឹងរៀបចំក្របខ័ណ្ឌច្បាប់មួយស្តីពីការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដើម្បីពង្រឹងការតាក់តែងច្បាប់ ឱ្យមានប្រសិទ្ធភាព និងធានាបាននូវការចូលរួមពីអ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ។

## ខ. ការងារសិទ្ធិមនុស្ស( អនុសាសន៍លេខ៦ និង២៩)

**អនុសាសន៍លេខ ៦**

៤០. រាជរដ្ឋាភិបាល បានយល់ព្រមជាគោលការណ៍ បង្កើតឱ្យមានស្ថាប័នសិទ្ធិមនុស្សជាតិតាមរយៈការរៀបចំឱ្យមានច្បាប់ ស្តីពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សជាតិដោយអនុលោមតាមគោលការណ៍ទីក្រុងប៉ារីស ដែលកន្លងមកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានសហការរៀបចំក្រុមការងារចម្រុះរបស់រាជរដ្ឋាភិបាល និងសង្គមស៊ីវិល ដោយប្រគល់ជូនក្រុមការងារសង្គមស៊ីវិល ជាអ្នកសរសេរសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិនេះ។

៤១. សេចក្តីព្រាងច្បាប់នេះ ត្រូវបានពិភាក្សាគ្នាជាច្រើនលើក ដែលរហូតមកដល់ពេលនេះនៅមិនទាន់ត្រូវបានបញ្ចប់នៅឡើយ។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា នឹងលើកយកសេចក្តីព្រាងច្បាប់នេះ មកធ្វើការពិគ្រោះយោបល់បន្ត ជាមួយភាគីពាក់ព័ន្ធ ជាពិសេសជាមួយការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ដើម្បីធ្វើឱ្យសេចក្តីព្រាងច្បាប់នេះ ស្របទៅនឹងគោលការណ៍ទីក្រុងប៉ារីស ដែលអាចទទួលយកបានស្របតាមស្ថានភាពនៃព្រះរាជាណាចក្រកម្ពុជា។[10]

**អនុសាសន៍លេខ ២៩**

**៤២.** កន្លងមក គ.ស.ម.ក. បានសហការជាមួយក្រសួង មន្ទីរពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន រួមទាំងភាគីពាក់ព័ន្ធផ្សេងៗទៀត ក្នុងការរៀបចំសិក្ខាសាលាស្តីពីសិទ្ធិមនុស្សនៅតាមបណ្តាខេត្តនានា ទូទាំងប្រទេស ក្នុងគោលបំណងបញ្ជ្រាប និងផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្សដល់សិក្ខាកាមទាំងអស់ ដែលជាមន្ត្រីអនុវត្តច្បាប់ អាជ្ញាធរមូលដ្ឋាន សិស្សនិស្សិត កម្មករ ប្រជាពលរដ្ឋ និងក្រុមជនជាតិដើមភាគតិចជាដើម។ កន្លងមក ក្រុមការងារ គ.ស.ម.ក. ក៏បានចុះអប់រំផ្សព្វផ្សាយស្តីពី **សិទ្ធិមនុស្ស និងច្បាប់** ដល់សិស្សតាមវិទ្យាល័យ និងគរុសិស្សតាមសាលាគរុកោសល្យនានា ដែលគិតពីដើមឆ្នាំ២០១៧មកដល់ខែកុម្ភៈ ឆ្នាំ២០១៩ មាន សិស្ស គរុសិស្ស និងប្រជាពលរដ្ឋចំនួន ៦ ៣៤០ នាក់ (ស្រីចំនួន ៣ ៧៤៨នាក់) បានទទួលការបណ្តុះបណ្តាល និងផ្សព្វផ្សាយស្តីពីសិទ្ធិមនុស្ស និងច្បាប់នេះ។[11] ក្រុមការងារ គ.ស.ម.ក. នឹងពង្រីកវិសាលភាពក្រុមគោលដៅនៃការអប់រំផ្សព្វផ្សាយស្តីពីសិទ្ធិមនុស្ស និងច្បាប់នេះ ឱ្យទៅដល់ប្រជាជនក្នុងសហគមន៍នៅតាមបណ្តារាជធានី ខេត្តនីមួយៗទូទាំងប្រទេសបន្ថែមទៀត។

**៤៣.** គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលកម្ពុជាក្នុងវិស័យសិទ្ធិមនុស្ស បានដាក់បញ្ចូលក្នុងគម្រោងថវិកាកម្មវិធីចំណាយរបស់ខ្លួនឆ្នាំ២០១៩ ដើម្បីធ្វើការផ្សព្វផ្សាយរបាយការណ៍សិទ្ធិមនុស្សនានា ដែលបានធ្វើជូនអង្គការសហប្រជាជាតិ តាមរយៈការបោះពុម្ពសៀវភៅរបាយការណ៍ និងការធ្វើបទបង្ហាញពាក់ព័ន្ធរបាយការណ៍ទាំងនេះជូនមន្ត្រីរាជការ សាធារណជន និងអ្នកពាក់ព័ន្ធនានា។

**គ. សមភាពយេនឌ័រ ការរើសអើងផ្អែកលើភេទ និងអំពើហិង្សាលើស្ត្រី (អនុសាសន៍លេខ ៧ ៩ និង១០)**

**អនុសាសន៍លេខ ៧**

**៤៤.** រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងវិធានការអនុវត្តច្បាប់ និងគោលនយោបាយនានា ឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីជានាសមភាពរវាងស្ត្រី និងបុរសនៅក្នុងគ្រប់វិស័យ តាមរយៈការបង្កើតយន្តការស្ថាប័នពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ។ នៅថ្នាក់ជាតិ រួមមានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងក្រសួងកិច្ចការនារី ហើយស្ថាប័នទាំង២នេះបានធ្វើសកម្មភាពតាមរយៈក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G) និងក្រុមសកម្មភាពបញ្ជ្រាបយេនឌ័រ(GMAGs) តាមក្រសួងស្ថាប័ន។ នៅថ្នាក់ក្រោមជាតិ រួមមានមន្ទីរកិច្ចការនារី គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង

[10] របាយការណ៍របស់ គសមក ធ្វើជូនគណៈកម្មាធិការជាតិកម្ពុជាប្រឆាំងទារុណកម្ម ខែធ្នូ ២០១៨

[11] របាយការណ៍ប្រចាំឆ្នាំ២០១៧/១៨ និង០២/២០១៩ របស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

កុមារ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ទូទាំងប្រទេសដែលមានតួនាទីលើកកម្ពស់សិទ្ធិស្ត្រី និងបញ្ជ្រាបយេនឌ័រ។

៤៥. ក្នុងតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាលកម្ពុជា ក្រសួងកិច្ចការនារី បានយកចិត្តទុកដាក់លើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងគ្រប់វិស័យទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការពង្រឹងការអនុវត្តច្បាប់ គោលនយោបាយជាតិ និងវិធានការសំខាន់ៗមានដូចជា៖

-ការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ឆ្នាំ១៩៩២ និងពិធីសារតាមជម្រើសឆ្នាំ២០១០ នៃអនុសញ្ញានេះ

-យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ដល់ទី៤

-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨

-ផែនការយុទ្ធសាស្ត្រ នារីរតនៈទី៤ (២០១៤-២០១៨)

-ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួងពាក់ព័ន្ធ (GMAPS)

-អនុសាសន៍របស់រាជរដ្ឋាភិបាល (តាមរយៈយន្តការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី)

-គោលការណ៍ណែនាំរបស់ក្រសួងមុខងារសាធារណៈ ក្នុងការជ្រើសរើសមន្ត្រីរាជការថ្មីជាស្ត្រី ដែលកំណត់ចំនួនពី២០% ទៅ៥០%។

៤៦. ស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងវិស័យនយោបាយ និងមុខងារសាធារណៈមានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងមុខតំណែង និងឋានន្តរសក្តិ ក៏ដូចជាក្នុងអង្គនីតិប្បញ្ញត្តិ អង្គនីតិប្រតិបត្តិ និងតុលាការ ដែលមានក្នុងតារាងខាងក្រោម៖

**ក្នុងអង្គនីតិប្បញ្ញត្តិ**

| នីតិកាល និងឆ្នាំ | សមាជិករដ្ឋសភា | | សមាជិកព្រឹទ្ធសភា | |
|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៣-២០១៨ | ១២៣ | ២៥ (២០.៣២%) | | |
| ២០១៧ | | | ៦២ | ១២ (១៩.៣៥%) |
| ២០១៨-២០២៣ | ១២៥ | ២៦ (២១%) | | |

**ក្នុងអង្គនីតិប្រតិបត្តិ**

| នីតិកាល និងឆ្នាំ | ឧបនាយករដ្ឋមន្ត្រី | | ទេសរដ្ឋមន្ត្រី | | រដ្ឋមន្ត្រី | | រដ្ឋលេខាធិការ | | អនុរដ្ឋលេខាធិការ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៣ | ៩ | ១(១១.១%) | ១៦ | 0 | ២៦ | ២(៧.១%) | ១៨៥ | ៣៨(២០.៥៤%) | ២៧៣ | ៤៨ (១៧.៥៨%) |
| ២០១៨ | ១០ | ១(១០%) | ១៧ | 0 | ២៩ | ៣ (១០.៣៤%) | ២៧៩ | ៤៥(១៥.៣៨%) | ៤៤០ | ៦៩ (១៥.៣៣%) |

**ស្ត្រីក្នុងតំណែងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

| អភិបាលរាជធានី ខេត្ត | | អភិបាលរងរាជធានី ខេត្ត | | អភិបាលក្រុង ស្រុក ខណ្ឌ | | អភិបាលរងក្រុង ស្រុក ខណ្ឌ | |
|---|---|---|---|---|---|---|---|
| សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២៥ | ១(៤%) | ១៥០ | ២៦ (១៧.៣%) | ១៩៧ | ៦(៣%) | ៧៧១ | ២០០ (២៥.៩%) |

**៤៧.** ស្ត្រីក្នុងប្រព័ន្ធតុលាការ និងច្បាប់បានកើនឡើងជាលំដាប់

| ឆ្នាំ | ចៅក្រម | | ព្រះរាជអាជ្ញា | | ក្រឡាបញ្ជី | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៣ | ២៦៥ | ៣៧ | ១៤៧ | ១៥ | ៦៣០ | ១៣៩ |
| ២០១៥ | ២៧៨ | ៤០ | ១៨៤ | ២៣ | ៦៣០ | ១៥៣ |
| ២០១៧ | ២៦៥ | ៣៨ | ១៨០ | ២៣ | ៧៦៦ | ១៦៥ |

**អនុសាសន៍លេខ ៩**

**៤៨.** នៅព្រះរាជាណាចក្រកម្ពុជា វិធានការការពារសិទ្ធិ និងការលុបបំបាត់ការរើសអើង និងអំពើហិង្សាលើអ្នកដែលស្រឡាញ់ភេទដូចគ្នា និងអ្នកភេទទី៣ ត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយជាតិចំនួន២គឺ ផែនការយុទ្ធសាស្ត្រជាតិស្តីពីសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រីលើកទី៤ (២០១៤-២០១៨)ហៅថាផែនការនារីរតនៈទី៤ និងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី២ (២០១៤-២០១៨)។ ក្នុងឆ្នាំ២០១៤ ក្រសួងកិច្ចការនារី បានធ្វើការវាយតម្លៃ និងរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងបញ្ហាយេនឌ័រនៅកម្ពុជា ហើយនៅក្នុងរបាយការណ៍នោះ បានពន្យល់យ៉ាងគ្រប់ជ្រុងជ្រោយអំពីទិដ្ឋភាពទូទៅនៃស្ថានភាពស្ត្រីកម្ពុជាលើគ្រប់វិស័យ ជាពិសេសស្ថានភាពអ្នកដែលស្រឡាញ់ភេទដូចគ្នា និងអ្នកភេទទី៣ និងបានលើកនូវអនុសាសន៍សំខាន់ៗមួយចំនួនដើម្បីការពារសិទ្ធិរបស់ពួកគេ។

**៤៩.** ដើម្បីឆ្លើយតបជាមួយស្ថានភាពនេះ ការដោះស្រាយចំពោះបញ្ហារើសអើង និងអំពើហិង្សាលើអ្នកដែលស្រឡាញ់ភេទដូចគ្នា និងអ្នកភេទទី៣ ត្រូវបានអនុវត្តស្របតាមគោលនយោបាយ និងតាមវិធីសាស្ត្រមានលក្ខណៈជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ ដោយបញ្ចូលភាពចម្រុះនៃភេទ និងអត្តសញ្ញាណយេនឌ័រទៅក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន។ វិធីសាស្ត្រនេះ មានគោលដៅគាំទ្រ និងពង្រឹងចំណេះដឹងជំនាញ និងទំនុកចិត្តរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំរួមទាំងអ្នកដែលនឹងក្លាយជាឪពុកម្តាយនាអនាគតក្នុងការចិញ្ចឹមកូនបែបវិជ្ជមាន ចាប់តាំងពីកកំណើតរហូតដល់អាយុក្រោម១៨ឆ្នាំ។

**៥០.** កម្មវិធីថ្មីមួយត្រូវបានបង្កើតឡើង មានឈ្មោះថា ត្រួសត្រាយផ្លូវ ដើម្បីសមភាពយេនឌ័រ ដែលបានការគាំទ្រពីអង្គការ UNDP និង Sida ដែលក្នុងកម្មវិធីនេះ បានផ្តោតលើការលើកកម្ពស់សិទ្ធិ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រីមកពីសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ កម្មវិធីនេះមានការចូលរួមពីក្រសួងពាក់ព័ន្ធចំនួន០៣ (ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមុខងារសាធារណៈ និងក្រសួងព័ត៌មាន) ដើម្បីអនុវត្តវិធាន

ការមួយចំនួនសម្រាប់បញ្ចូលក្រុមស្ត្រី និងក្មេងដែលងាយរងគ្រោះចំនួន៥ក្រុម រួមមានស្ត្រីមកពីសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ស្ត្រី និងក្មេងស្រីឥស្លាម និងជនជាតិដើមភាគតិច ស្ត្រីចំណាស់ និងស្ត្រី និងក្មេងស្រីពិការ។ វិធីសាស្ត្រជំរុញ និងការពារសិទ្ធិអ្នកដែលស្រឡាញ់ភេទដូចគ្នា គឺការជំរុញឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា ដើម្បីបញ្ចប់នូវការមាក់ងាយ និងអំពើហិង្សាលើពួកគេ។

**៥១.** ក្រសួងកិច្ចការនារី បាននិងកំពុងរៀបចំដាក់បញ្ចូលស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកភេទទីពីទៅក្នុងជំពូកក្រុមស្ត្រី និងក្មេងស្រីងាយរងគ្រោះ សម្រាប់ការធ្វើបច្ចុប្បន្នភាពលើការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាឆ្នាំ២០១៨។ ជាមួយគ្នានេះ សេចក្តីព្រាងគោលនយោបាយជាតិស្តីពី សមភាពយេនឌ័រ ក៏នឹងត្រូវដាក់បញ្ចូលបញ្ហាក្រុមស្ត្រី និងក្មេងងាយរងគ្រោះផងដែរ។

**អនុសាសន៍លេខ ១០**

**៥២.** រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ ២០០៩-២០១២ ដែលក្រសួងកិច្ចការនារី បានបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិល ដើម្បីរួមគ្នាឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ(TWGG-GBV) ឱ្យបានជោគជ័យ និងទទួលបានលទ្ធផល ដោយអនុវត្តតាមយុទ្ធសាស្ត្រមានជាអាទិ៍ (១)បង្កើនការយល់ដឹងជាសាធារណៈតាមរយៈ ការចែកចាយច្បាប់ និងការផ្សព្វផ្សាយច្បាប់យ៉ាងទូលំទូលាយដល់អ្នកពាក់ព័ន្ធ និងអង្គការដៃគូ (២)កែលម្អប្រព័ន្ធសេវាគាំទ្រឱ្យមានភាពងាយស្រួលក្នុងការរក និងទទួលបានសេវាគាំទ្រកាន់តែមានប្រសិទ្ធភាព។ ទន្ទឹមនេះ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ និងមន្ត្រីនគរបាលបានចូលរួមយ៉ាងសកម្មក្នុងការឆ្លើយតបចំពោះករណីអំពើហិង្សាលើស្ត្រី។

**៥៣.** ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានសម្របសម្រួលផ្តល់សេវាផ្នែកច្បាប់ជូនស្ត្រីរងគ្រោះដោយអំពើហិង្សាតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ នៃមន្ទីរកិច្ចការនារីរាជធានី ខេត្ត បានចំនួន ៨៧ ករណី រួមមានអំពើហិង្សាក្នុងគ្រួសារ ៣៣ករណី រំលោភសេពសន្ថវៈ ៥៣ករណី និងករណីប្រទូសកេរ្តិ៍ខ្មាស ០១ករណី ក្នុងនោះជនរងគ្រោះជាអនីតិជន ៤០ ករណី នៅឆ្នាំ២០១៥ - ២០១៦។ ដោយមានកិច្ចសហការល្អជាមួយអាជ្ញាធរមានសមត្ថកិច្ច និងតុលាការ មន្ត្រីនគរបាលយុត្តិធម៌ បានពន្លឿនករណីអំពើហិង្សាលើស្ត្រី និងកុមារ ជាពិសេស ករណីការបញ្ជូនសំណុំរឿងអនីតិជនទៅស្ថាប័នតុលាការ តាមនីតិវិធីច្បាប់។ ក្រសួងយុត្តិធម៌ បានបន្តផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិស្ត្រី និងកុមារ នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងការស្នុំកូនដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីអនុវត្តច្បាប់ចំនួន១៧០០នាក់(ស្ត្រី៥៨៤នាក់) ក្នុងឆ្នាំ២០១៦-២០១៧។

**ឃ. សណ្ដាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ (អនុសាសន៍លេខ ៨ ១២ ១៣ ១៤ ១៦ ១៨ ២១ ២២ និង ២៧ )**

**អនុសាសន៍លេខ ៨**

**៥៤.** ប្រទេសកម្ពុជា ជាសមាជិកហត្ថលេខីនៃអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងបានក្លាយជារដ្ឋភាគីនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៨៣។

អនុលោមតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា និងស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញាខាងលើនេះ ព្រះរាជាណាចក្រកម្ពុជាបានកំណត់ការរើសអើងពូជសាសន៍ ជាបទល្មើសព្រហ្មទណ្ឌដោយឱ្យនិយមន័យនៃពាក្យ "ការរើសអើងពូជសាសន៍" គឺមានន័យថា ការបដិសេធក្នុងការផ្ដល់ទ្រព្យសម្បត្តិ ឬ សេវា ការបដិសេធក្នុងការជួលបុគ្គលឱ្យធ្វើការ ការបណ្ដេញចេញ ឬ ដកហូតបុគ្គលណាម្នាក់ និងការបដិសេធក្នុងការផ្ដល់សិទ្ធិដោយអ្នករាជការសាធារណៈដោយផ្អែកលើមូលហេតុ ឬដោយមានលក្ខខណ្ឌដោយបុគ្គលនោះជាសមាជិក ឬមិនមែនជាសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ឬពូជសាសន៍ណាមួយជាកំណត់ គឺជាការរើសអើងដែលត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ ដូចមានបញ្ញត្តិពីមាត្រា២៦៥ ដល់មាត្រា២៧០ នៃក្រមព្រហ្មទណ្ឌ។

**៥៥.** អនុលោមតាមគោលការណ៍ច្បាប់ខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងសកម្មដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើង ដែលប្រកាន់ពូជសាសន៍និយម ប្រឆាំងនឹងជនជាតិបរទេសភាគតិច ជាពិសេសចំពោះជនជាតិភាគតិចវៀតណាម ដែលចូលមករស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**៥៦.** កន្លងមកនេះ អាជ្ញាធរមានសមត្ថកិច្ច បានធ្វើការត្រួតពិនិត្យលក្ខណៈសម្បត្តិផ្លូវច្បាប់ទៅលើជនជាតិភាគតិចបរទេសទាំងអស់ ដែលបាននិងកំពុងរស់នៅធ្វើការងារនៅក្នុងប្រទេសកម្ពុជា ដែលក្នុងនេះអាជ្ញាធរបានរកឃើញ ជនជាតិភាគតិចវៀតណាមមានចំនួនច្រើនជាងគេ ដែលចូលមករស់នៅដោយខុសច្បាប់ ហើយត្រូវបានអាជ្ញាធរមានសមត្ថកិច្ច ចាប់បញ្ជូនត្រឡប់ទៅប្រទេសដើមវិញដោយអនុលោមតាមបញ្ញត្តិ នៃច្បាប់ស្ដីពីអន្តោប្រវេសន៍របស់ព្រះរាជាណាចក្រកម្ពុជា។

**អនុសាសន៍លេខ ១២**

**៥៧.** ការប្រមូលផ្ដុំរបស់ក្រុមបាតុករខុសច្បាប់កាលពីថ្ងៃទី០២-០៣ ខែមករា ឆ្នាំ២០១៤ ពុំមែនជាសកម្មភាពប្រមូលផ្ដុំធ្វើបាតុកម្មទាមទារ តវ៉ាបែបអហិង្សានោះទេ។ ការប្រមូលផ្ដុំនេះ ជាការប្រមូលផ្ដុំប្រព្រឹត្តអំពើហិង្សា តាមរយៈសកម្មភាពដុតបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជនពីសំណាក់ក្រុមបាតុករ ដោយមានការចូលរួមញុះញង់ និងលើកទឹកចិត្តពីមេដឹកនាំ និងបានត្រៀមបម្រុងទុករួចជាស្រេចនូវមធ្យោបាយសម្រាប់ប្រយុទ្ធ និងធ្វើការបំផ្លិចបំផ្លាញ ដូចជា ដុំថ្ម ដុំឥដ្ឋ ដំបង ដបសាំងសម្រាប់ធ្វើការវាយប្រហារតែម្ដង ដែលក្នុងព្រឹត្តិការណ៍នោះបានធ្វើឱ្យកងកម្លាំងនគរបាលជាតិរងរបួស

ចំនួន១៦នាក់ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេសរងរបួសចំនួន០១នាក់ផងដែរ។ ក្នុងព្រឹត្តិការណ៍នេះ អាជ្ញាធរបានប្រើប្រាស់កម្លាំងសរុបដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់មិនហួសហេតុនោះឡើយ ដើម្បីទប់ទល់ទៅនឹងក្រុមមនុស្សរាប់ពាន់នាក់ ដែលមានអាវុធគ្រប់ដៃត្រៀមប្រយុទ្ធជាស្រេចនោះ។ ជាការឆ្លើយតបទៅនឹងបាតុកម្មដោយហិង្សាក្នុងទ្រង់ទ្រាយបែបនេះ អាជ្ញាធរបានប្រើកម្លាំងមានសមត្ថកិច្ចតាមគ្រប់មធ្យោបាយជំនាញសមស្រប ដើម្បីបង្ការទប់ស្កាត់ឱ្យបានទាន់ពេលវេលា រក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដោយពុំអនុញ្ញាតឱ្យអំពើនេះរីករាលដាលកាន់តែធំថែមទៀតបានឡើយ។

**៥៨.** ព្រឹត្តិការណ៍ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ និងថ្ងៃទី២-៣ ខែមករា ឆ្នាំ២០១៤ ដែលបង្កឡើងដោយក្រុមបាតុករខុសច្បាប់នោះ មិនមែនជាបាតុកម្មដោយសន្តិវិធីនោះទេ។ ក្រុមបាតុករខុសច្បាប់មានការចាត់តាំងប្រដាប់ដោយអាវុធឧបករណ៍ប្រល័យ មានដុំថ្ម ដុំឥដ្ឋ ដំបងបំពង់ទីបដំរចាក់ស៊ីម៉ងត៍ខាងក្នុង និងសាំងដប។ល។ បញ្ចេញនូវសកម្មភាពហិង្សាទៅលើកងកម្លាំងការពារសន្តិសុខដែលមានភារកិច្ចការពារសន្តិសុខ ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ជូនប្រជាពលរដ្ឋស្របតាមកាតព្វកិច្ច និងតួនាទីដែលបានកំណត់ក្នុងច្បាប់ជាធរមាន។

**៥៩.** ទោះបីយ៉ាងណាក៏ដោយ អាជ្ញាធរមានសមត្ថកិច្ច (ក្រសួងមហាផ្ទៃ) បានធ្វើការស៊ើបអង្កេតលើព្រឹត្តិការណ៍នេះទាំងមូលតែម្តង ដើម្បីធ្វើការប៉ាន់ស្មានប្រៀបធៀបទុកជាបទពិសោធន៍សម្រាប់ការងារតទៅមុខទៀត។ ករណីនេះបើធ្វើការប្រៀបធៀបនឹងឃើញដូចតទៅៈ

១.អំពីបរិមាណកម្លាំងឃើញថា ក្រុមបាតុករមានច្រើនលើសលប់លើកម្លាំងរបស់អាជ្ញាធរ

២.អំពីអាវុធឃើញថាអាវុធរបស់កម្លាំងអាជ្ញាធរមានឥទ្ធិពលខ្លាំងជាង ប៉ុន្តែបរិមាណតិចជាងយ៉ាងច្រើនបើប្រៀបធៀបទៅនឹងអាវុធរបស់ក្រុមបាតុករ។

៣.កម្លាំងរបស់អាជ្ញាធរ ធ្វើសកម្មភាពក្នុងពេលដែលក្រុមបាតុករ បានប្រើហិង្សាបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជន។ សកម្មភាពរបស់កម្លាំងអាជ្ញាធរ គឺដើម្បីការពារទ្រព្យសម្បត្តិសាធារណៈ ដែលនេះគឺជាសច្ចធារណ៍ការពារស្របច្បាប់របស់អាជ្ញាធរ ដែលមិនមែនជាការប្រើប្រាស់កម្លាំងហួសហេតុដើម្បីបង្ក្រាបក្រុមបាតុករនោះទេ។

**អនុសាសន៍លេខ ១៣**

**៦០.** រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតយន្តការបង្ការថ្នាក់ជាតិប្រឆាំងនឹងអំពើទារុណកម្ម ដែលមានឈ្មោះថា"គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម (គ.ជ.ប.ទ)" តាមព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦១៩ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ ដែលមានសមាជិកចំនួន៩រូប និងមានលេខាធិការដ្ឋានមួយជាសេនាធិការ។ គណៈកម្មាធិការនេះ ធ្វើការដោយឯករាជ្យលើមុខងារស្របតាមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងទទួលទំនាក់ទំនងជាមួយអនុគណៈកម្មាធិការប្រឆាំងទារុណកម្មអ.ស.ប ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ។ អនុលោមតាមព្រះរាជក្រឹត្យខាងលើនេះ អនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២១០៨ និងលិខិតលេខ ១២០៣ សជណ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ បានប្រគល់ភារកិច្ចឱ្យគណៈកម្មាធិការនេះ ចុះអប់រំ ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តជាតិ អន្តរជាតិដែលពាក់ព័ន្ធនឹងការធ្វើទារុណកម្ម

និងការចុះអង្កេតត្រួតពិនិត្យពន្ធនាគារ ទីកន្លែងឃុំឃាំងបណ្ដោះអាសន្ននានា នៅតាមរាជធានី/ខេត្ត ដោយមិនផ្ដល់ដំណឹងជាមុន។

**៦១**. នៅព្រះរាជាណាចក្រកម្ពុជា ក្នុងគ្រប់ករណីចម្លើយសារភាពដែលបានមកពីការបង្ខិតបង្ខំតាមផ្លូវកាយក្ដី តាមផ្លូវចិត្តក្ដី ឬការធ្វើទារុណកម្ម មិនអាចយកជាការបានឡើយ ដូចមានចែងនៅក្នុងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ លើមូលដ្ឋាននៃបទប្បញ្ញត្តិច្បាប់ខាងលើនេះ នគរបាលយុត្តិធម៌មិនមានសិទ្ធិអំណាច ធ្វើការបង្ខិតបង្ខំតាមផ្លូវកាយក្ដី ផ្លូវចិត្តក្ដី ឬការធ្វើទារុណកម្មជនសង្ស័យ ដើម្បីយកចម្លើយនោះទេ ព្រោះថាចម្លើយបែបនេះពុំអាចធ្វើជាភស្តុតាងបានឡើយ ហើយមន្ត្រីដែលធ្វើទារុណកម្មជនសង្ស័យនឹងត្រូវទទួលទោសតាមក្រមព្រហ្មទណ្ឌជាធរមាន។

**៦២**. ទន្ទឹមនេះជនរងគ្រោះនៃអំពើទារុណកម្ម អាចដាក់ពាក្យប្ដឹងទាមទារសំណងការខូចខាត និងសំណងជំងឺចិត្តពីជនល្មើស ដូចមានចែងក្នុងមាត្រា២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[12] ក្នុងករណីការអះអាងមួយចំនួនដែលជនជាប់ចោទមានភស្តុតាង ស្លាកស្នាមបញ្ជាក់អោយឃើញថា ពិតជាមានការធ្វើទារុណកម្មពិតប្រាកដមែន តុលាការតែងតែបានធ្វើការស្រាវជ្រាវចោទប្រកាន់ និងផ្ដន្ទាទោសអាជ្ញាធរដែលបានប្រព្រឹត្តអំពើទារុណកម្មនេះទៅតាមអំពើដែលបានប្រព្រឹត្តមានជាអាទិ៍៖

-ករណីទី១ នគរបាលយុត្តិធម៌ចំនួន ៥រូប ត្រូវបានតុលាការខេត្តព្រះសីហនុ សម្រេចផ្ដន្ទាទោសពីបទបង្ករបួសស្នាមដោយចេតនាតាមសាលក្រមព្រហ្មទណ្ឌលេខ២៧យ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១០។

-ករណីទី២ នគរបាលយុត្តិធម៌ចំនួន ២រូប ត្រូវបានតុលាការខេត្តព្រះសីហនុ សម្រេចផ្ដន្ទាទោសពីបទហិង្សាដោយចេតនាតាមសាលក្រមព្រហ្មទណ្ឌលេខ ៣៩ង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០១៣។

**៦៣**. ការអះអាងរបស់ជនត្រូវចោទខ្លះដែលថា នគរបាលធ្វើទារុណកម្មដើម្បីយកចម្លើយ ប៉ុន្តែពុំមានភស្តុតាងច្បាស់លាស់ ហើយតុលាការពុំអាចរកភស្តុតាងឃើញ គឺស្ថិតនៅភាពវិមតិសង្ស័យទាំងការធ្វើទារុណកម្ម ទាំងក្នុងអង្គសេចក្ដីនៃបទចោទប្រកាន់ តុលាការបានផ្ដល់ប្រយោជន៍ដល់ជនជាប់ចោទជាអាទិ៍៖ នៅចំពោះមុខចៅក្រមស៊ើបសួរនៃតុលាការខេត្តឧត្តរមានជ័យ ជនត្រូវចោទម្នាក់បាននិយាយថាខ្លួនត្រូវបាននគរបាលធ្វើទារុណកម្ម ប៉ុន្តែពុំមានភស្តុតាងបញ្ជាក់ច្បាស់លាស់ ហើយចៅក្រមក៏រកភស្តុតាងដាក់បន្ទុកពុំបាន ចៅក្រមបានសម្រេចលើកលែងចោទ ជនត្រូវចោទឱ្យមានសេរីភាពវិញ។

**៦៤**. ទន្ទឹមនឹងនេះ ក៏មានសមត្ថកិច្ចខ្លះ បានប្រើហិង្សាទៅលើជនល្មើសក្នុងឱកាសប្រតិបត្តិការផងដែរ ដូចជា កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ នៅភូមិតាបែ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង មាននគរបាលម្នាក់បានធ្វើប្រតិបត្តិការចាប់ជនសង្ស័យដែលឈ្លោះវាយតប់គ្នា។ ក្នុងពេលនោះនគរបាលម្នាក់ បានវាយទៅលើជនសង្ស័យម្នាក់ ឱ្យមានរបួស។

នគរបាលនោះ ត្រូវបានចោទប្រកាន់ពីបទហិង្សាដោយចេតនាហើយត្រូវបានតុលាការខេត្តស្វាយរៀង សម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារចំនួន ៣ឆ្នាំ ដោយព្យួរទោស និងសងសំណងជំងឺចិត្តជាប្រាក់ចំនួន

[12] របាយការណ៍ក្រសួងមហាផ្ទៃលេខ ២១៥១សជណចុះថ្ងៃទី១២ ធ្នូ ឆ្នាំ ២០១៨

៥.០០០ ០០០រៀល (ប្រាំលានរៀល)តាមសាលក្រមព្រហ្មទណ្ឌលេខ ១០៧ធ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦។[13]

**អនុសាសន៍លេខ ១៤**

**៦៥.** ដើម្បីដោះស្រាយបញ្ហាចង្អៀតណែននៅតាមពន្ធនាគារ ក្រសួងមហាផ្ទៃ បានសាងសង់អគារបន្ថែម ចំនួន១២អគារ និងកែច្នៃហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ដោយសង់ជាផ្នើតាមបន្ទប់ឃុំ ដើម្បីពង្រីក លទ្ធភាពក្នុងការផ្ទុកចំណុះ បានចំនួន២៧អគារដោយបានកែច្នៃ និងជួសជុលអគារផ្សេងៗទៀតធ្វើជា អគារឃុំ បានចំនួន២៥អគារ ដែលអាចបង្កើនផ្ទៃអគារឃុំបន្ថែមបានចំនួន៣០,៤៥៤ ម៉ែត្រក្រឡា។ ទោះជាយ៉ាងនេះក្តី ការសាងសង់ និងកែច្នៃអគារឃុំបន្ថែម គ្រាន់តែជាដំណោះស្រាយសម្រាប់រយៈពេល ខ្លីប៉ុណ្ណោះ វិធានការចាំបាច់ជាលក្ខណៈប្រព័ន្ធមួយចំនួនទៀត សម្រាប់រយៈពេលវែង ដែលរាជរដ្ឋាភិ បាលកម្ពុជាកំពុងពិចារណា រួមមាន៖

-ការអនុវត្តទោសការងារសហគមន៍ជាគោល ដែលកន្លងមកនេះរាជរដ្ឋាភិបាល បានបញ្ជូនមន្ត្រី ជាន់ខ្ពស់ទៅធ្វើទស្សនៈកិច្ចសិក្សានៅប្រទេសជប៉ុន និងប្រទេសថៃ។

-ព្រមជាមួយគ្នានេះ ការពិភាក្សាតុមូលជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដូចជា ICRC UNICEF JICA ដើម្បីស្វែងរកវិធានការ និងវិធីសាស្ត្រដោះស្រាយបញ្ហាចង្អៀតណែននៅតាម ពន្ធនាគារ។

-ការកសាងប្រព័ន្ធទិន្នន័យជនជាប់ឃុំ សម្រាប់ពង្រឹងការគ្រប់គ្រង និងតាមដានសំណុំរឿងជន ជាប់ឃុំជាមួយតុលាការ សំដៅពន្លឿនដំណើរការកាត់ក្តី និងអនុវត្តគោលនយោបាយលើកលែង និង បន្ធូរបន្ថយទោសឱ្យកាន់តែប្រសើរឡើង។

-ការបង្កើតសាលាឧទ្ធរណ៍តំបន់ចំនួន៣ទៀត ដើម្បីពន្លឿនដំណើរការកាត់ក្តី កាត់បន្ថយការ ចំណាយ និងភាពកកកុញនៅពន្ធនាគារ និងមណ្ឌលអប់រំកែប្រែនៅរាជធានីភ្នំពេញ ពេលជនជាប់ឃុំ ត្រូវបានបញ្ជូនពីពន្ធនាគារខេត្តនានាមករង់ចាំឡើងសវនាការនៅសាលាឧទ្ធរណ៍ ដែលបច្ចុប្បន្នមានតែ មួយនៅភ្នំពេញ។

**៦៦.** ចំពោះសេវាគាំពារសុខភាពដែលមិនទាន់មានគ្រប់គ្រាន់ អគ្គនាយកដ្ឋានពន្ធនាគារ បាននិង កំពុងចាត់វិធានការទំនាក់ទំនង និងសហការជាមួយមន្ទីរពេទ្យបង្អែកខេត្ត មន្ទីរពេទ្យរដ្ឋ និងមន្ទីរពេទ្យ នគរបាល១៦ឧសភា នៅរាជធានីភ្នំពេញ ដើម្បីជួយផ្តល់សេវាថែទាំសុខាភិបាល និងសម្ភពស្ត្រីដល់អ្នក ជាប់ឃុំ។ បន្ថែមលើនោះទៀត អគ្គនាយកដ្ឋានពន្ធនាគារ ក៏បានសហការល្អជាមួយអង្គការក្រៅរដ្ឋា ភិបាល និងសង្គមស៊ីវិលសម្រាប់កម្មវិធីទប់ស្កាត់ជំងឺឆ្លងដូចជា របេង អេដស៍ ជំងឺកមរមាស់ និងការ បណ្តុះបណ្តាលស្តីពីការថែទាំសុខភាព អនាម័យទូទៅក្នុងពន្ធនាគារ។

**៦៧.** បញ្ហាសុខភាពផ្លូវចិត្តក៏ដូចជាសុខភាពផ្លូវកាយរបស់ជនជាប់ឃុំដែរ ថ្វីត្បិតតែអត្រាជនជាប់ឃុំ ដែលមានអាការវិកលចរិត ឬទទួលរងបញ្ហាសុខភាពផ្លូវចិត្តកន្លងមកនៅមានកម្រិតទាបនៅឡើយ ក៏ អគ្គនាយកដ្ឋានពន្ធនាគារទទួលស្គាល់ពីកង្វះខាតនៃអ្នកជំនាញប្រចាំការផ្នែកសុខភាពផ្លូវចិត្ត និងជំងឺ

[13]ចំនុច ១១ និង ១២នៃការឆ្លើយតបអនុសាសន៍ទាំងបី របស់កម្ពុជាចំពោះអង្គការសហប្រជាជាតិ

វិកលចរិតនៅតាមពន្ធនាគារ កង្វះខាតធនធាន និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ថែទាំអ្នកមានបញ្ហាសុខភាពផ្លូវចិត្ត។ ក្រៅពីនោះអត្រាជនជាប់ឃុំធ្វើទុក្ខកិរិយា (Self-harm) ក៏មានកម្រិតទាប ប្រៀបធៀបទៅនឹងប្រទេសក្នុងតំបន់ និងប្រទេសអភិវឌ្ឍន៍មួយចំនួន។ ទោះយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជា បន្តយកចិត្តទុកដាក់ខ្ពស់លើសុខភាពផ្លូវចិត្តរបស់ជនជាប់ឃុំ តាមរយៈការបញ្ចូលកម្មវិធីសាសនា (ព្រះពុទ្ធសាសនា សាសនាអ៊ីស្លាម គ្រីស្តសាសនា) និងវិបស្សនាអប់រំផ្លូវចិត្តទៅក្នុងកម្មវិធីអប់រំជនជាប់ឃុំ។ ទន្ទឹមនេះ អគ្គនាយកដ្ឋានពន្ធនាគារ បានសហការជាមួយអង្គការ TPO Cambodia (កម្មវិធីសុខភាពផ្លូវចិត្ត)ដើម្បីជួយព្យាបាលសុខភាពផ្លូវចិត្តតាមបែបវិទ្យាសាស្ត្រដល់អ្នកជាប់ឃុំផងដែរ។

**៦៨**. សម្រាប់ការកាត់បន្ថយពេលវេលារបស់ជនជាប់ឃុំ ដើម្បីចេញក្រៅបន្ទប់ឃុំមកធ្វើលំហាត់ប្រាណប្រចាំថ្ងៃ មិនត្រូវបានអនុវត្តនៅគ្រប់ពន្ធនាគារទេ។ ផ្អែកលើកត្តាសន្តិសុខ ពេលវេលាសម្រាប់ជនជាប់ឃុំម្នាក់ៗនៅក្រៅបន្ទប់ឃុំត្រូវបានកាត់បន្ថយនៅតាមពន្ធនាគារណា ដែលមានភាពចង្អៀតណែនខ្លាំង ដូចជានៅមណ្ឌលអប់រំកែប្រែទី១ មណ្ឌលអប់រំកែប្រែទី២ និងពន្ធនាគារខេត្តសៀមរាបជាដើម ដើម្បីសម្រួលឱ្យជនជាប់ឃុំបានចេញមកក្រៅគ្រប់ៗគ្នា។

**៦៩**. ចំពោះអំពើពុករលួយ និងអំពើខុស កំហុសឆ្គងរបស់មន្ត្រីអនុរក្សពន្ធនាគារ អាជ្ញាធរមានសមត្ថកិច្ចបានយកចិត្តទុកដាក់ខ្ពស់ធ្វើការស៊ើបអង្កេតស្រាវជ្រាវពីភាពមិនប្រក្រតី នៅតាមពន្ធនាគារទូទាំងប្រទេស ដោយមានការចូលរួមពីសំណាក់អង្គភាពពាក់ព័ន្ធមានសមត្ថកិច្ចដទៃទៀត ដូចជាអគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង គណៈកម្មាធិការជាតិទប់ស្កាត់ការធ្វើទារុណកម្ម ជាពិសេសអនុគណៈកម្មាធិការទប់ស្កាត់ការធ្វើទារុណកម្មរបស់អង្គការសហប្រជាជាតិ។ល។ គិតមកទល់ពេលនេះ មានមន្ត្រីពន្ធនាគារចំនួន៥៩នាក់ ត្រូវបានដាក់ឱ្យអនុវត្តវិន័យរដ្ឋបាល ក្រោយពីបានរកឃើញថាពួកគេបានប្រព្រឹត្តអំពើខុសឆ្គងពាក់ព័ន្ធនឹងតួនាទី។ អគ្គនាយកដ្ឋានពន្ធនាគារ ក៏តែងលើកទឹកចិត្តឱ្យជនជាប់ឃុំរាយការណ៍ផ្ទាល់មកអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ ឬ ទៅស្ថាប័នមានសមត្ថកិច្ចរួមមាន អង្គភាពប្រឆាំងអំពើពុករលួយ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ល។ ក្នុងករណីមានការបំពានណាមួយដោយខុសច្បាប់ពីសំណាក់មន្ត្រីអនុរក្សនៅតាមពន្ធនាគារនីមួយៗ។

**៧០**. ពាក់ព័ន្ធនឹងភាពយឺតយ៉ាវក្នុងការដោះលែងអ្នកទោស ដែលបានអនុវត្តទោសចប់តាមសាលក្រមតុលាការហើយនោះ មានមិនដល់១%ទេ ដោយហេតុថាការបំពេញបែបបទដោះលែងមានការយឺតដោយប្រការផ្សេងៗ។ ក្រៅពីនេះ មានទណ្ឌិតខ្លះដែលផុតទោសហើយមិនបានចេញទៅផ្ទះភ្លាមទេ តែបានស្នើសុំសម្រាកនៅពន្ធនាគារបន្តមួយរយៈសិនទើបធ្វើដំណើរត្រឡប់ទៅភូមិកំណើតវិញ ដែលករណីបែបនេះ ធ្វើឱ្យមានការភាន់ច្រឡំថា អាជ្ញាធរពន្ធនាគារបង្ខាំងអ្នកទោសដោយបំពាន។ ដើម្បីលុបបំបាត់ករណីយឺតយ៉ាវបែបនេះ អគ្គនាយកដ្ឋានពន្ធនាគារបានណែនាំទៅពន្ធនាគាររាជធានី ខេត្ត និងមណ្ឌលអប់រំកែប្រែ ឱ្យពិនិត្យជាប្រចាំលើសំណុំរឿងរបស់ទណ្ឌិតដើម្បីធ្វើទំនាក់ទំនងជាមួយស្ថាប័នតុលាការ ឱ្យជួយរៀបចំបែបបទដោះលែងឱ្យបានលឿនទាន់ពេលវេលាចំពោះទណ្ឌិត ដែលបានអនុវត្តទោសចប់ជាស្ថាពរតាមអំណាចសាលក្រម។[14]

[14] របាយការណ៍ក្រសួងមហាផ្ទៃលេខ ២១៥១សជណចុះថ្ងៃទី១២ ធ្នូ ឆ្នាំ ២០១៨

**អនុសាសន៍លេខ ១៦**

**៧១.** អាជ្ញាធរមានសមត្ថកិច្ច ពុំបានធ្វើការចាប់ខ្លួន ឬឃុំខ្លួន ជនគ្មានផ្ទះសម្បែង អ្នកសុំទាន ជនអនាថាគ្មានទីពឹង អ្នកប្រើប្រាស់គ្រឿងញៀន កុមារតាមចិញ្ចើមផ្លូវ និងអ្នករកស៊ីផ្លូវភេទដោយបំពាននោះទេ តែអាជ្ញាធរបានធ្វើការប្រមូលជនទាំងនេះ យកទៅប្រគល់ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីអប់រំស្តារនីតិសម្បទា គាំពារសុខភាពប្រកបដោយគោលការណ៍មនុស្សធម៌។

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មាធិការជាតិសម្រាប់ដោះស្រាយបញ្ហាខាងលើនេះ តាមអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ ដើម្បីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការៈ

-បង្កើតឱ្យមានយុទ្ធសាស្ត្ររួមសម្រាប់ដោះស្រាយបញ្ហាជនប្រភេទនេះ ដោយរួមមានបញ្ចូលការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ និងបង្ការទប់ស្កាត់ការវិលត្រឡប់មកសុំទានវិញ។

-ពង្រឹង ពង្រីកបណ្តាញការងារសម្រាប់ដោះស្រាយបញ្ហាជនប្រភេទនេះ នៅគ្រប់លំដាប់ថ្នាក់ដើម្បីផ្តល់សេវាដល់ជនទាំងនោះ មានលំនឹងក្នុងការកសាងជីវភាពរស់នៅដោយខ្លួនឯង។

**៧២.** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានទទួលមុខសញ្ញាពីការប្រមូលរបស់ អាជ្ញាធរមានសមត្ថកិច្ច រួមមានជនគ្មានផ្ទះសម្បែង អ្នកសុំទាន កុមារតាមចិញ្ចើមផ្លូវ និងអ្នករកស៊ីផ្លូវភេទ មកស្នាក់នៅក្នុងមជ្ឈមណ្ឌលដើម្បីផ្តល់នូវការការពារសុវត្ថិភាព ការស្នាក់នៅ ការហូបចុក ការថែទាំសុខភាព អប់រំផ្លូវចិត្ត ការប្រឹក្សាយោបល់ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈខ្លីៗ ការស្តារនីតិសម្បទា និងធ្វើសមាហរណកម្មទៅកាន់គ្រួសារ និងសហគមន៍ដោយស្ម័គ្រចិត្ត ស្របតាមគោលការណ៍សិទ្ធិមនុស្សប្រកបដោយមនុស្សធម៌ គឺមិនធ្វើការចាប់ខ្លួន និងឃុំខ្លួនជនទាំងនេះដោយបំពាននោះទេ។

ចំពោះអ្នកញៀនគ្រឿងញៀន គឺមជ្ឈមណ្ឌល ទទួលយកអ្នកញៀនគ្រឿងញៀនតាមការបញ្ជូនរបស់តុលាការ និងស្ថាប័នមានសមត្ថកិច្ច ឬទទួលយកអ្នកញៀនគ្រឿងញៀនដែលស្ម័គ្រចិត្តទទួលសេវាពីមជ្ឈមណ្ឌល។

**៧៣.** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏ដូចជាស្ថាប័នមានសមត្ថកិច្ច និអង្គការសង្គមស៊ីវិលជានិច្ចកាលបានចុះធ្វើការត្រួតពិនិត្យ និងស៊ើបអង្កេតលើកិច្ចដំណើរការនៃមណ្ឌលថែរក្សាជនគ្មានផ្ទះសម្បែង អ្នកសុំទាន កុមារតាមចិញ្ចើមផ្លូវ អ្នករកស៊ីផ្លូវភេទ រួមទាំងអ្នកញៀនគ្រឿងញៀន ដើម្បីតាមដានមើលពីករណីប្រព្រឹត្តមិនគប្បីពីសំណាក់បុគ្គលិកនៃមណ្ឌលទាំងនោះ។ ប៉ុន្តែរហូតមកដល់ពេលនេះពុំមានភស្តុតាងណាមួយបង្ហាញបញ្ជាក់ពីករណីការធ្វើទារុណកម្ម ឬអំពើមិនគប្បីណាមួយនោះឡើយ ។

**អនុសាសន៍លេខ ១៨**

**៧៤.** ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតយន្តការជាតិហៅថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានក្រសួងចំនួន២១ និងអង្គភាពជំនាញ

ចំនួន៥ ជាសមាជិក និងមានវិសាលភាពពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ។ គណៈកម្មាធិការជាតិនេះដឹកនាំដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ អន្តរជាតិ តំបន់ និងអនុតំបន់ អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិ សំដៅផ្សព្វផ្សាយអប់រំដល់ស្រទាប់មហាជនក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងបង្ក្រាបអំពើជួញដូរមនុស្សឱ្យមានប្រសិទ្ធភាព។

**៧៥.** កាលពីឆ្នាំ២០១៧កន្លងទៅនេះ អាជ្ញាធរមានសមត្ថកិច្ចបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន១៥៩ករណី (លើ៩២ករណីបើធៀបនឹងឆ្នាំ២០១៦ កើនឡើងចំនួន៦៧ករណី ស្មើនឹង ៧២.៨២%)។ ក្នុងនេះ ឃាត់ខ្លួនជនសង្ស័យ និងបញ្ជូនទៅតុលាការ បានចំនួន២០៣/១១៣នាក់ (កើនឡើងចំនួន៩០នាក់) មានស្រី៦១នាក់ និងអនីតិជន១៧នាក់ ត្រូវបានចាប់ខ្លួន។ ក្នុងនោះជនសង្ស័យដែលជាជនបរទេសមានចំនួន២០នាក់ មាន០៨សញ្ជាតិគឺ វៀតណាម០៣នាក់ អង់គ្លេស០២នាក់ ហូឡង់០២នាក់ ជប៉ុន០១នាក់ អាមេរិក០១នាក់ រុស្ស៊ី០១នាក់ ចិន០៩នាក់ និងឆេក០១នាក់។

ទន្ទឹមនេះដែរក្នុងឆ្នាំ២០១៧នោះ តុលាការមានសំណុំរឿងពាក់ព័ន្ធនឹងការជួញដូរមនុស្សចំនួន២៧០ករណី ដែលមានជនជាប់ចោទចំនួន៣២៣នាក់ (ស្ត្រី៧០នាក់)។ ក្នុងនោះតុលាការបានសម្រេចផ្តន្ទាទោសជនល្មើសដាក់ពន្ធនាគារក្នុងឃុំចំនួន១២៩នាក់ និងក្រៅឃុំចំនួន៤៥នាក់។

**៧៦.** ដោយឡែកជនរងគ្រោះ ដែលសង្គ្រោះបានក្នុងករណីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទក្នុងឆ្នាំ២០១៧ សរុបបានចំនួន៣៤៥/២៩៨នាក់ (កើនចំនួន៤៧នាក់) ក្នុងនោះអាយុក្រោម១៥ឆ្នាំមាន១៣៨នាក់ អាយុពី១៥-១៧ឆ្នាំ មាន៤០នាក់ និងអាយុ១៨ឆ្នាំឡើង មាន១៦៧នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ច ចំនួន១២០នាក់ ទៅអង្គការចំនួន០៥នាក់ និងទៅបញ្ជូនទៅគ្រួសារវិញបានចំនួន២២០នាក់)។

**៧៧.** ព្រមជាមួយនឹងការបង្ក្រាប ចាប់ជនល្មើសផ្តន្ទាទោសតាមច្បាប់ អាជ្ញាធរមានសមត្ថកិច្ច បានយកចិត្តទុកដាក់ផងដែរចំពោះជនរងគ្រោះដែលត្រូវបានគេធ្វើអាជីវកម្មនៅក្រៅប្រទេស ហើយត្រូវបានធ្វើមាតុភូមិនិវត្តន៍ មានដូចតារាងខាងក្រោមនេះ

| ស្ថាប័នដែលបានទទួលជនដែលសង្ស័យថារងគ្រោះ | ចំនួនជនដែលសង្ស័យថារងគ្រោះ | | |
|---|---|---|---|
| | ប្រុស | ស្រី | កុមារ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៤៦ | ១១៩ | |
| មជ្ឈមណ្ឌលសំចតប៉ោយប៉ែត | ២៤៣ | ១ | ២៧ |
| មន្ទីរសង្គមកិច្ចរាជធានី ខេត្ត | ២៣៨ | ១៩៧ | |
| អង្គការដៃគូ | ៣៤២ | ១៣៦ | ១៩៣ |
| *សរុប* | *៨៦៩ នាក់* | *៤៥៣ នាក់* | *២២០* |

៧៨. ជនដែលសង្ស័យថារងគ្រោះ ដែលបានធ្វើមាតុភូមិនិវត្តន៍ មួយចំនួនបានទទួលសំណងមានដូចខាងក្រោម៖

- ចំនួន**២៧**នាក់ ក្រោយពីការតវ៉ាក្តីនៅប្រទេសថៃចប់ ទទួលបានសំណង៖

  - ចំនួន**០៦**នាក់ ទទួលបានថវិកាពី(SDSW) ដោយម្នាក់ៗទទួលបានចំនួន**៣.០០០** បាត។

  - ចំនួន**២១**នាក់ ទទួលបានថវិកាខុសៗគ្នាទៅតាមការខូចខាតរបស់សាមីខ្លួនពីថៅកែថៃ (ឆ្នាំ២០១៧)។

  - បុរសចំនួន**១២**នាក់ បានធ្វើមាតុភូមិនិវត្តន៍ និងទទួលថវិកាសំណងពីថៅកែថៃ ក្នុងម្នាក់ៗទទួលបាន**៦២.០០០**បាត។

- ស្ត្រីខ្មែរ ចំនួន**០៥**នាក់ កាលពីខែកុម្ភៈ ឆ្នាំ២០១៨ ក្រោមការជួយអន្តរាគមន៍ពីស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន និងនគរបាលជប៉ុនបានទទួលសំណងសរុប**១០២.៤៧១**ដុល្លារអាមេរិក ពីក្រុមហ៊ុននៅខេត្ត Tochigi ជប៉ុន។

៧៩. ក្នុងឆ្នាំ២០១៧ ជនដែលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ដែលត្រូវបានជួយសង្គ្រោះ មួយចំនួនត្រូវបានអាជ្ញាធរមានសមត្ថកិច្ចធ្វើសមាហរណកម្មទៅគ្រួសារវិញ ដែលមានដូចតារាងខាងក្រោម៖

| **ក្រសួង ស្ថាប័ន** | **ជនដែលសង្ស័យថារងគ្រោះ** | | |
|---|---|---|---|
| | **ប្រុស** | **ស្រី** | **កុមារ** |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១៨៨ | ១៧២ | ០៨ |
| មន្ទីរសង្គមកិច្ចរាជធានី ខេត្ត | ១៣ | | |
| អង្គការដៃគូ | ១៧២ | ១៥៦ | ០៨ |
| ***សរុប*** | ***៣៧៣ នាក់*** | ***៣២៨ នាក់*** | ***១៦ នាក់*** |

**អនុសាសន៍លេខ ២១**

៨០. គ្រប់បទល្មើសព្រហ្មទណ្ឌទាំងអស់ ដែលបានកើតឡើង អាជ្ញាធរមានសមត្ថកិច្ចជាពិសេសមន្ត្រីនគរបាលយុត្តិធម៌តែងធ្វើការស៊ើបអង្កេត ប្រមូលភស្តុតាង កំណត់អត្តសញ្ញាណជនល្មើស និងចាប់ជនល្មើស ដើម្បីយកមកផ្តន្ទាទោសតាមច្បាប់ ទោះបីបទល្មើសនោះមានកម្រិតធ្ងន់ធ្ងរ ឬស្រាលយ៉ាងណាក៏ដោយ។

៨១. អ្នកកាសែត និងតួអង្គសង្គមស៊ីវិលផ្សេងៗទៀតក៏មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានកាតព្វកិច្ចគោរពច្បាប់ដូចបុគ្គលផ្សេងទៀតដែរ។ អ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស និងតួអង្គសង្គមស៊ីវិលផ្សេងៗទៀត ដែលប្រព្រឹត្តល្មើសច្បាប់ត្រូវផ្តន្ទាទោសដូចបុគ្គលផ្សេងទៀតដែរ។

នៅព្រះរាជាណាចក្រកម្ពុជា ការសម្តែងមតិមិនមែនជាបទល្មើសទេ ប៉ុន្តែការប្រើប្រាស់វិជ្ជាជីវៈរបស់ខ្លួន ឬការសម្តែងមតិធ្វើជាមធ្យោបាយ ដើម្បីប្រព្រឹត្តអំពើណាមួយ ដែលច្បាប់ហាមឃាត់គឺជាបទ

ល្មើសត្រូវផ្តន្ទាទោសតាមច្បាប់។ រយៈកាលកន្លងមកនេះ មានអ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស និងតួអង្គសង្គមស៊ីវិលផ្សេងទៀតមួយចំនួន ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់តាមច្បាប់ជាធរមាន។ ករណីសម្រេចផ្តន្ទាទោសនេះ មិនមែនដើម្បីធ្វើជាមធ្យោបាយនៃការធ្វើឱ្យញញើត ឬបង្អាក់ទឹកចិត្តដល់ពួកអ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស និងតួអង្គសង្គមស៊ីវិលដទៃទៀតនោះទេ។ ការផ្តន្ទាទោសទាំងនេះ គឺដោយសារតែពួកគេបានយកវិជ្ជាជីវៈធ្វើជាមធ្យោបាយដើម្បីប្រព្រឹត្តបទល្មើស។

៨២. តាមមាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ របស់ព្រះរាជាណាចក្រកម្ពុជា បទបរិហាកេរ្តិ៍មិនត្រូវបានដាក់ទោសពន្ធនាគារទេ។ ការដាក់បទបរិហារកេរ្តិ៍ជាទោសព្រហ្មទណ្ឌដោយពិន័យជាប្រាក់នេះ គឺជាការកំណត់នូវករណីយកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើស ឱ្យចេះទទួលស្គាល់ចំពោះអំពើរបស់ខ្លួន។ ករណីនេះ គឺស្របនឹងកថាខណ្ឌទី៣ មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនមែនដើម្បីរឹតត្បិតសិទ្ធិសេរីភាពនៃការបញ្ចេញមតិនោះទេ។

៨៣. សេចក្តីព្រាងច្បាប់ ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មានវិទ្យា បាននិងកំពុងពិនិត្យ និងកែសម្រួលដោយក្រសួងមហាផ្ទៃ សហការជាមួយអ្នកជំនាញការច្បាប់តំណាងក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក។ សេចក្តីព្រាងច្បាប់នេះ មានលក្ខណៈល្អប្រសើរស្របទៅតាមលក្ខខណ្ឌតម្រូវនៃមាត្រា១៩ កថាខណ្ឌទី៣ និងមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាប៊ុយដាប៉េសស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មានវិទ្យា ( Budapest, 23.XI.2001 Convention On Cybercrime ) ។

៨៤. ក្រសួងមហាផ្ទៃ បានផ្តួចផ្តើមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនាពាក់កណ្តាលឆ្នាំ១៩៩៥ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័ននានា និងមានការគាំទ្របច្ចេកទេសពីអ្នកជំនាញការច្បាប់អង្គការអន្តរជាតិ និងអ្នកជំនាញការបរទេសមួយចំនួន។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំវេទិកា ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា បួនលើក មុននឹងរដ្ឋសភា និងព្រឹទ្ធសភាបានធ្វើការអនុម័ត។

ជារួម ច្បាប់នេះត្រូវបានរៀបចំឡើងឈរលើមូលដ្ឋាន នៃរដ្ឋធម្មនុញ្ញ និងច្បាប់នានាជាធរមានរបស់កម្ពុជា រួមនឹងលិខិតតូបករណ៍អន្តរជាតិដែលប្រទេសកម្ពុជា បានទទួលស្គាល់ ព្រមទាំងបទពិសោធន៍នានាជាអន្តរជាតិ ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាច្រើនដំណាក់កាលស្របតាមដំណើរការ និងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ដោយចំណាយរយៈពេលប្រមាណជាង២០(ម្ភៃ)ឆ្នាំ។

៨៥. ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ច្បាប់នេះ មានគោលបំណងសំខាន់ៗ រួមមាន៖

- ធានាការពារសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ និងផល

ប្រយោជន៍សាធារណៈ ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈ ដើម្បីអភិវឌ្ឍសង្គមកម្ពុជាលើគ្រប់វិស័យ។

-ធានានូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងជីវភាពនយោបាយ ទោះបីបុគ្គលនោះជាមេដឹកនាំ ឬជាសមាជិក នៃអង្គការមិនមែនរដ្ឋាភិបាលក៏ដោយ។ ប៉ុន្តែការធ្វើសកម្មភាពក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាលក្នុងន័យគាំទ្រ ឬប្រឆាំងទៅនឹងគណបក្សនយោបាយណាមួយ ត្រូវបានហាមឃាត់ដោយច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**៨៦.** រហូតមកដល់ពេលបច្ចុប្បន្ននេះ មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកបានតម្កល់សំណុំឯកសារ និងចុះបញ្ជីមានចំនួនសរុប ៥.៥០៧ក្នុងនោះមានសមាគមចំនួន២.២៨៦ និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន**៣.២២១**។ គិតមកដល់ត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០១៨ បន្ទាប់ពីច្បាប់នេះបានចូលជាធរមាន មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ មានចំនួន**សរុប៩០៩** ក្នុងនោះមានសមាគមចំនួន**៥០៩** និងអង្គការមិនមែនរដ្ឋាភិបាលមាន**ចំនួន៤០០**។ រហូតមកដល់ពេលនេះ មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលប្រមាណជា ២.០០០ ហើយដែលបានបំពេញកាតព្វកិច្ចស្របតាមគោលការណ៍ ដែលបានកំណត់ក្នុងការធ្វើរបាយការណ៍ប្រចាំឆ្នាំ។

**៨៧.** ផ្អែកលើទិន្នន័យខាងលើនេះ បង្ហាញថាមិនមានការថយចុះចំនួននៃការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះឡើយ។ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការស្របតាមគោលការណ៍នីតិរដ្ឋ ក៏ដូចជាសម្រួលដល់ការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឱ្យធ្វើសកម្មភាពស្របច្បាប់ ស្របតាមលក្ខន្តិកៈរបស់ខ្លួន ក្រសួងមហាផ្ទៃ បានរៀបចំសិក្ខាសាលាថ្នាក់ជាតិមួយ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ ដោយមានអ្នកចូលរួមប្រហែល ៥០០នាក់ មកពីក្រសួងពាក់ព័ន្ធ រួមមានស្ថាប័នរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។

**៨៨.** រាជរដ្ឋាភិបាល បានចាត់ទុកសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាដៃគូសហប្រតិបត្តិការក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងគ្រប់វិស័យទាំងអស់នៃការអភិវឌ្ឍសង្គម។ កាលពីពេលថ្មីៗនេះ ដោយទទួលបានមតិត្រឡប់ពីដៃគូអភិវឌ្ឍន៍ថា អង្គការមិនមែនរដ្ឋាភិបាល ឬសមាគម រងការគំរាមកំហែង ឬការបំភិតបំភ័យពីអាជ្ញាធរមូលដ្ឋានក្នុងការធ្វើសកម្មភាពរបស់ពួកគេនៅថ្នាក់មូលដ្ឋាន ក្រសួងមហាផ្ទៃ បានរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនាពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដើម្បីពិនិត្យឡើងវិញនូវស្ថានភាពកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ និងដើម្បីកំណត់អំពីបញ្ហាប្រឈមនានារបស់អង្គការសង្គមស៊ីវិលទាំងអស់ និងដើម្បីស្វែងរកវិធានការដោះស្រាយ ដោយធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការ ដោយមានអ្នកចូលរួមប្រមាណ ៤០០នាក់មកពីគ្រប់ក្រសួងស្ថាប័ននានា នៃរាជរដ្ឋាភិបាលកម្ពុជា មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលចំនួន២០០។

៨៩. ដើម្បីដោះស្រាយនូវកង្វល់ សំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិលដែលបានលើកឡើង រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបង្កើតក្រុមការងារមួយ ដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល ដែលមានសមាសភាពមកពីក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈសេចក្តីសម្រេចលេខ៨៤ សសរ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨។ ទន្ទឹមនេះផងដែរ ក្រសួងមហាផ្ទៃ ក៏បានដាក់ចេញនូវសេចក្តីណែនាំលេខ០៤០ សណន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ព្រមទាំងសហគមន៍នានានៅមូលដ្ឋាន។ តាមរយៈសេចក្តីណែនាំនេះ ក្រសួងមហាផ្ទៃក៏បានផ្ញើលិខិតជូនដំណឹងទៅគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ដើម្បីជានាឱ្យសមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅមូលដ្ឋាន មានសិទ្ធិសេរីភាពពេញលេញក្នុងការធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ព្រមទាំងលក្ខន្តិកៈរបស់ខ្លួន ដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយពុំចាំបាច់ជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានក្នុងរយៈពេល០៣ថ្ងៃ មុនពេលចាប់ផ្តើមធ្វើសកម្មភាពដូចមុននោះឡើយ។[15] ចំពោះកង្វល់ សំណើ និងសំណូមពរនានារបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្រសួងមហាផ្ទៃនឹងធ្វើការដោះស្រាយដោយសហការជាមួយតំណាងអង្គការសង្គមស៊ីវិល ស្របតាមវិធានច្បាប់ និងនីតិវិធីជាធរមាន។

### អនុសាសន៍លេខ ២២

៩០. យោងទៅតាមច្បាប់ ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី បាតុករមានសិទ្ធិក្នុងការធ្វើបាតុកម្ម ប៉ុន្តែមិនត្រូវបង្កឱ្យមានអំពើហិង្សាប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈឡើយ។ ក្នុងករណីដែលបាតុកម្មដោយសន្តិវិធីប្រែក្លាយទៅជាអំពើហិង្សា បាតុករត្រូវទទួលខុសត្រូវទៅតាមច្បាប់កំណត់។ បាតុករដែលគោរពទៅតាមបទប្បញ្ញត្តិនៃ មាត្រា២ មាត្រា៥ មាត្រា១៦ និងមាត្រា២០នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវទទួលបានការធានាការពារពីអាជ្ញាធរសាធារណៈ នៅក្នុងការអនុវត្តសិទ្ធិនៃការធ្វើបាតុកម្មរបស់ខ្លួន។

### អនុសាសន៍លេខ ២៧

៩១. រាជរដ្ឋាភិបាល បាននិងកំពុងរៀបចំក្របខណ្ឌច្បាប់ ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ដោយអនុលោមតាមកាតព្វកិច្ចជាអន្តរជាតិ ដែលកម្ពុជាជាហត្ថលេខី រួមទាំងការធានាដល់ការចុះបញ្ជីអត្រានុកូលដ្ឋានកំណើត ជូនដល់កុមារគ្រប់រូបដោយមិនរើសអើងអំពីស្ថានភាពនៃក្រុមគ្រួសាររបស់ពួកគេឡើយ។ ការចុះបញ្ជីនេះ នឹងធ្វើតាមប្រព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានដែលអាចគ្រប់គ្រងបានអត្តសញ្ញាណបុគ្គលជាក់លាក់ ជឿទុកចិត្តបាន សម្រាប់ជាមូលដ្ឋានក្នុងការអនុវត្តសិទ្ធិសេរីភាព ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងជួយបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវារដ្ឋបាល

[15] លិខិតលេខ២០០៦ សជណ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ

និងសេវាតម្រូវការនានាជូនសាធារណជន។ ការងារនេះ ជាសមាសធាតុយ៉ាងសំខាន់បំផុតក្នុងការលើកកម្ពស់សមធម៌ និងយុត្តិធម៌សង្គម ជាពិសេសបានផ្ដោតការយកចិត្តទុកដាក់ដល់ក្រុមជនងាយរងគ្រោះ ក្រុមជនជាតិដើមភាគតិច ក៏ដូចជាបុគ្គលគ្មានរដ្ឋដែរ។

**៩២.** នៅព្រះរាជាណាចក្រកម្ពុជា ការចុះបញ្ជីកំណើតកុមារ និងការទទួលបានសញ្ជាតិខ្មែរមានច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត កំណត់អំពីនីតិវិធីច្បាស់លាស់ ដែលការអនុវត្តនីតិវិធីទាំងពីរនេះ ពុំមានការរើសអើងនោះឡើយ។ សូម្បីកុមារគ្មានរដ្ឋ ក៏អាចចុះបញ្ជីកំណើតដាក់លាក់បានដែរ។ ទោះបីយ៉ាងនេះក៏ដោយ ការទទួលបានសញ្ជាតិខ្មែរនាពេលបច្ចុប្បន្ននេះត្រូវគោរព និងអនុលោមតាមលក្ខខណ្ឌ ដែលបានកំណត់ក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

### ង.អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### អនុសាសន៍ ១៩

**៩៣.** អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានបង្កើតឡើងដោយ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដើម្បីកាត់ទោសបទឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ កម្ពុជា និងអង្គការសហប្រជាជាតិ បានគាំទ្រ អ.វ.ត.ក ចាប់តាំងពីតុលាការនេះ បានចាប់បដិសន្ធិមកម្ល៉េះ ហើយនឹងបន្តការគាំទ្ររហូតដល់បញ្ចប់អាណត្តិរបស់ខ្លួន។ ចៅក្រម សហព្រះរាជអាជ្ញា និងមន្ត្រីច្បាប់ទាំងអស់នៅ អ.វ.ត.ក បាននិងកំពុងបំពេញការងារ និងធ្វើសេចក្ដីសម្រេចដោយឯករាជ្យ ដោយគ្មានការជ្រៀតជ្រែកណាមួយឡើយ។ កម្ពុជាក៏ដោយ អង្គការសហប្រជាជាតិក៏ដោយ មិនអាចសម្រេច ឬបញ្ចប់កិច្ចស៊ើបសួរ/កិច្ចដំណើរការនីតិវិធីបានឡើយ មានតែស្ថាប័នតុលាការប៉ុណ្ណោះ ដែលអាចធ្វើការសម្រេចបាន។ កាលពីចុងឆ្នាំ២០១៨ កន្លងមកនេះ នៅក្នុងអំឡុងកិច្ចប្រជុំជាមួយ ឯកឧត្តម Miguel de Serpa Soares អគ្គលេខាធិការរង អ.ស.ប. ទទួលបន្ទុកកិច្ចការច្បាប់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប៊ិន ឈិន ប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកសាលាក្ដីខ្មែរក្រហម បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា គាំទ្រ និងចង់ឃើញ អ.វ.ត.ក បំពេញ និងបញ្ចប់អាណត្តិរបស់ខ្លួនតាមនីតិវិធីត្រឹមត្រូវ ដោយសេចក្ដីថ្លៃថ្នូរ និងកិត្តិយស"។[16]

### ច. សិទ្ធិបោះឆ្នោតរបស់ជនជាប់ឃុំ

### អនុសាសន៍២៦

**៩៤.** ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋមិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត ដូចមានចែងក្នុងមាត្រា៤៦ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ(ច.ប.ត.រ.) និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ។

-ចំពោះជនមានសតិវិបល្លាស មានន័យថាជននោះបាត់បង់នូវសតិមួយផ្នែកណាមួយ ដែលមិនអាចឱ្យគាត់មានការគិត និងធ្វើការបែងចែកខុសត្រូវ ដូចជនមានសតិពេញលេញឡើយ។ ហេតុនេះបើ

---

[16] របាយការណ៍ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អនុញ្ញាតឱ្យពួកគាត់មានសិទ្ធិក្នុងការបោះឆ្នោតនោះ ការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយតម្លាភាព និងសុក្រឹតភាពបានឡើយ។

-ជារួមការតាក់តែងច្បាប់ទាំងឡាយ គឺស្ថាប័នមានសមត្ថកិច្ចបានគិតគូរយ៉ាងច្បាស់ពីផលប៉ះពាល់ និងភាពស្របទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ[17] និងសន្ធិសញ្ញានានា ដែលប្រទេសកម្ពុជា ជាភាគីហត្ថលេខីរួចទៅហើយ។[18]

**៩៥.** យោងមាត្រា ៣១ (មួយ) និងមាត្រា ៣៤ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កំណត់ពីការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិបោះឆ្នោត។

យោងមាត្រា ៤៦ នៃច.ប.ត.រ. បានចែងថា "ដើម្បីបោះឆ្នោតបានប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ"។

ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានអាយុ ១៨ ឆ្នាំឡើងទៅ គិតទៅដល់ថ្ងៃបោះឆ្នោត
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវបោះឆ្នោត
- មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត
- ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័ន មានសមត្ថកិច្ច។

**៩៦.** នៅព្រះរាជាណាចក្រកម្ពុជា ជនដែលមានសតិវិបល្លាស ឬជនវិកលចរិត ត្រូវបានបាត់បង់សិទ្ធិក្នុងការបោះឆ្នោតផងដែរ (មាត្រា៤៦ នៃ ច.ប.ត.រ. លក្ខខណ្ឌដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត)។ ទន្ទឹមនឹងការបាត់បង់សិទ្ធិបោះឆ្នោត ជនមានសតិវិបល្លាស ក៏ត្រូវបានច្បាប់ចែង ឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ។ ការណ៍ដែលច្បាប់កំណត់បែបនេះ ដោយផ្អែកលើមូលហេតុថា ជនដែលកើតវិបល្លាស ឬជនវិកលចរិតបានបាត់បង់សមត្ថភាពខាងបញ្ញាស្មារតី ពោលគឺបាត់បង់សមត្ថភាពក្នុងការទទួលខុសត្រូវរបស់ខ្លួន ដែលមិនអាចធានាបានពីការសម្រេចចិត្ត ទៅតាមឆន្ទៈពិតប្រាកដនោះឡើយ។

**៩៧.**ជាគោលការណ៍ លក្ខខណ្ឌជាទណ្ឌិតដែលស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារមិនអាចទទួលបាននូវបណ្តាសិទ្ធិទាំងឡាយដូចពលរដ្ឋទូទៅនោះទេ ពោលគឺសិទ្ធិមួយចំនួនត្រូវបានដកហូតដោយច្បាប់។ បទប្បញ្ញត្តិពាក់ព័ន្ធនឹងការដកសិទ្ធិរបស់ជនដែលស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ នៃប្រទេសនីមួយៗក្នុងសកលលោក គឺមានលក្ខណៈខុសៗគ្នា អាស្រ័យទៅតាមស្ថានភាពជាក់ស្តែងនៃប្រទេសទាំងនោះ។

---

[18] លិខិតលេខ១៥៤៣ គ.ជ.ប ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

៩៨. នៅព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្ន ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មិនអនុញ្ញាតឱ្យទណ្ឌិតដែលជាប់ឃុំឃាំង មានសិទ្ធិក្នុងការបោះឆ្នោតនោះឡើយ (មាត្រា ៤៦ លក្ខខណ្ឌដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត)។

➢ មានកត្តាមួយចំនួន ដែលមិនអនុញ្ញាតឱ្យជនដែលជាប់ឃុំឃាំង មានសិទ្ធិបោះឆ្នោតៈ

-ការគ្រប់គ្រងពន្ធនាគារ ពុំទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ធានាពីសន្តិសុខ និងសុវត្ថិភាពនៅឡើយ

- ប្រព័ន្ធបោះឆ្នោតសមាមាត្រ ដោយយករាជធានី ខេត្តជាមណ្ឌលបោះឆ្នោត មិនអំណោយផលដល់ការរៀបចំការបោះឆ្នោតក្នុងពន្ធនាគារ

- កុំឱ្យអ្នកនយោបាយយកការលើកលែងទោស និងការបន្ធូរបន្ថយទោសដល់ទណ្ឌិត ធ្វើជាគោលនយោបាយ ដើម្បីឃោសនាទាក់ទាញសំឡេងឆ្នោតពីទណ្ឌិត។ ព្រោះការធ្វើបែបនេះ គឺជាការផ្តល់ឱកាសដល់ឧក្រិដ្ឋជនផ្សេងៗ អាចរួចផុតពីទោសជាប់ពន្ធនាគារដោយងាយស្រួល។

ទោះបីជាសិទ្ធិបោះឆ្នោតត្រូវបានដកហូតជាបណ្តោះអាសន្នយ៉ាងណាក៏ដោយ ទណ្ឌិតនៅតែមានសិទ្ធិដទៃជាច្រើនទៀត ជាពិសេសសិទ្ធិជាមូលដ្ឋានដូចមានចែងក្នុង សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលអនុម័ត និងប្រកាសដោយសេចក្តីសម្រេច នៃមហាសន្និបាតអង្គការសហប្រជាជាតិលេខ២១៧ A នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

**ធ. សិទ្ធិជនជាតិដើមភាគតិច និងដីធ្លី**

**អនុសាសន៍លេខ ២៨**

៩៩. រាជរដ្ឋាភិបាល មានគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍសហគមន៍ជនជាតិដើមភាគតិច ដែលបានអនុម័តក្នុងឆ្នាំ២០០៩។ គោលនយោបាយនេះ មានគោលដៅលើកស្ទួយកម្រិតជីវភាពរស់នៅជនជាតិដើមភាគតិច ព្រមទាំងថែរក្សាវប្បធម៌ ប្រពៃណីល្អ ទំនៀមទម្លាប់ និងជំនឿរបស់ពួកគាត់។[19]

**១០០.** នៅព្រះរាជាណាចក្រកម្ពុជា ជនជាតិដើមភាគតិច មានសិទ្ធិលើដីធ្លីលើសពីប្រជាពលរដ្ឋទូទៅ គឺអាចចងក្រងជាសហគមន៍ទទួលបានសិទ្ធិកម្មសិទ្ធិសមូហភាព និងអាចមានសិទ្ធិជាកម្មសិទ្ធិឯកជនដូចប្រជាពលរដ្ឋទូទៅ ដែលត្រូវបានធានានិងការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ភូមិបាលឆ្នាំ២០០១។[20]

**១០១.** រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ និងអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ត្រូវបានដាក់ចេញដោយឆ្លងកាត់ការពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងមានការចូលរួមពីអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ ពិសេសសហគមន៍ជនជាតិដើមភាគតិចតែម្តង ក្នុងគោលបំណងលើកស្ទួយជីវភាព

[19] លិខិតលេខ២១៥១សជណចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ

រស់នៅរបស់ជនជាតិដើមភាគតិច រក្សាទំនៀមទម្លាប់ វប្បធម៌ ប្រពៃណីល្អ ជំនឿផ្សេងៗតាមកុលសម្ព័ន្ធ ការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ ដែលជាមូលដ្ឋានក្នុងការលើកកម្ពស់ជីវភាពរស់នៅ និងគុណភាពនៃជីវិត។

**១០២**. ក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ខ្ពស់គិតគូរអំពីតម្រូវការសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងដើម្បីឱ្យប្រជាពលរដ្ឋទទួលបានអត្ថប្រយោជន៍ជាអាទិ៍ៈ

- អភិវឌ្ឍសកម្មភាពកសិកម្មប្រពលវប្បកម្ម និងកសិឧស្សាហកម្ម

- បង្កើនភាពមានការងារធ្វើនៅជនបទក្នុងក្របខណ្ឌ នៃការធ្វើប្រពលវប្បកម្ម និងការធ្វើឱ្យមានកាលានុវត្តភាព នៃការរកទទួលទានចិញ្ចឹមជីវិតមានលក្ខណៈសម្បូរណ៍បែប ការអនុវត្តផលិតកម្មតាមកិច្ចសន្យា និងការគ្រប់គ្រងធនធានធម្មជាតិតាមប្រព័ន្ធអេកូឡូស៊ីសមស្រប។

- ផ្តល់ការងារជូនប្រជាពលរដ្ឋនៅជនបទ ឱ្យទទួលបាននូវមុខរបរថ្មីបន្ថែមពីលើមុខរបរដែលមានស្រាប់។ ជាក់ស្តែងមានប្រជាពលករប្រមាណជា ៥១.៣១៩នាក់ បានទទួលការងារធ្វើនៅលើដីសម្បទានសេដ្ឋកិច្ច។

- មានហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវ សាលារៀន មណ្ឌលសុខភាព និងសេវាកម្មជាច្រើនទៀត ដែលជាក់ស្តែងក្រុមហ៊ុនបានកសាងផ្លូវបានប្រវែង ១៣.៨៦៧គីឡូម៉ែត្រ។

**១០៣**. ក្នុងការអនុវត្តគោលនយោបាយដោះស្រាយការប៉ះពាល់ផ្នែកសង្គមកិច្ច ជាក់ស្តែងមានជាអាទិ៍ៈ

១. គម្រោងវារីអគ្គិសនីសេសានក្រោម២ មានផលប៉ះពាល់ប្រជាពលរដ្ឋចំនួន៦ភូមិ ក្នុងឃុំ៣ ដែលមានប្រជាពលរដ្ឋសរុបចំនួន៨៦០គ្រួសារ/ខ្នងផ្ទះ ត្រូវបានរាជរដ្ឋាភិបាលដោះស្រាយគោលនយោបាយទូទាត់សំណងជូនប្រជាពលរដ្ឋបានចំនួន៨១៤គ្រួសារ/ខ្នងផ្ទះ ស្មើនឹង ៩៤.៥% នៅសល់ ៤៦គ្រួសារ/ខ្នងផ្ទះ ស្មើនឹង ៥.៥% ទៀត ដែលកំពុងពិភាក្សាសម្របសម្រួលបន្ត។ សំណងដែលផ្តល់ជូនប្រជាពលរដ្ឋរួមមានៈ

- រៀបចំភូមិថ្មីដោយមានហេដ្ឋារចនាសម្ព័ន្ធសាធារណៈគ្រប់គ្រាន់។

- សង់ផ្ទះជូនគ្រួសារនីមួយៗមានទំហំ៨០ម៉ែត្រក្រឡាលើទំហំផ្ទៃដី២០ម៉ែត្រ គុណនឹង ៥០ ម៉ែត្រ។

- ផ្តល់ដីកម្មសិទ្ធិទំហំ៥ហិចតាក្នុងមួយគ្រួសារ។

- ឧបត្ថម្ភជួយសម្រួលដល់ការកសាងជីវិតថ្មី ក្នុងរយៈពេលមួយឆ្នាំមានជាអាទិ៍ស្បៀង ប្រេងសម្រាប់ដុតបំភ្លឺ គ្រាប់ពូជដំណាំផ្សេងៗ និងថ្នាំការពារផលដំណាំ។

- ព្រមទាំងបានផ្តល់នូវដីព្រៃអាស្រ័យផលអនុផលព្រៃឈើ ដីបញ្ចុះសព និងដីសែនព្រេនអារក្សអ្នកតាតាមទំនៀមទម្លាប់របស់សហគមន៍។

២. គម្រោងរុករកប្រេងកាតបានរកឃើញតំបន់មួយប៉ះពាល់ដល់ដីស្រែចំនួន៤ហិចតា ដែលជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋចំនួន៣គ្រួសារ។ ក្រុមហ៊ុនបានធ្វើការចរចារ ពិភាក្សា និងឯកភាពគ្នាជាមួយនឹងគ្រួសារដែលរងផលប៉ះពាល់ ដោយក្រុមហ៊ុនជួលយកដី៤ហិចតានោះតាមតម្លៃព្រមព្រៀង ដើម្បីធ្វើប្រតិបត្តិការ។ ប៉ុន្តែបច្ចុប្បន្ន គម្រោងនេះត្រូវបានរាជរដ្ឋាភិបាលកម្ពុជា លុបចោលវិញហើយ។

**១០៤.** វឌ្ឍនភាពនៃការងារដោះស្រាយវិវាទដីធ្លីពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ចដំណាំអំពៅ ផលិតស្ករសនាំចេញ នៅខេត្តគោលដៅទាំង៤ រួមមាន ខេត្តកោះកុង ខេត្តកំពង់ស្ពឺ ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ មានលទ្ធផលដូចខាងក្រោម៖

**១. ខេត្តកោះកុង**

**១០៥.** ក្រុមហ៊ុនចំនួន៣ ពាក់ព័ន្ធនឹងវិវាទដីសម្បទានសេដ្ឋកិច្ចដំណាំអំពៅផលិតស្ករសនាំចេញនៅខេត្តកោះកុង គឺក្រុមហ៊ុន Koh kong plantation Co.,Ltd ក្រុមហ៊ុន Koh kong SugarIndustry Co.,Ltd និងក្រុមហ៊ុន ហេង ហ៊ុយ អភិវឌ្ឍន៍។ ការដោះស្រាយវិវាទបានបញ្ចប់ជាស្ថាពរជូនប្រជាពលរដ្ឋ ដែលពាក់ព័ន្ធទាំង ៩៨៦គ្រួសារក្នុងនោះ៖

១.១. ក្រុមប្រជាពលរដ្ឋ ១៧៥គ្រួសារទទួលបានដីទំហំ ៣ហិកតា និងថវិកា ២.៥០០ដុល្លារក្នុងមួយគ្រួសារស្ថិតនៅឃុំដងពែង និងឃុំជីខលើ ស្រុកស្រែអំបិល និងឃុំកណ្ដោល ស្រុកបូទុមសាគរ។

១.២. ក្រុមប្រជាពលរដ្ឋ ២០០គ្រួសារ ទទួលបានដីទំហំ ១.៥ហិកតា ក្នុងមួយគ្រួសារ ស្ថិតនៅឃុំជីខលើ ស្រុកស្រែអំបិល។ ប្រជាពលរដ្ឋក្នុងក្រុម ១៧៥ និងក្រុម ២០០គ្រួសារ បានទទួលថវិកា ចាប់ឆ្នោតទទួលដីឡូតិ៍ និងបានចូលទៅកាន់កាប់ប្រើប្រាស់ដីរួចរាល់ហើយ និងបានប្រកាសតំបន់វិនិច្ឆ័យចុះបញ្ជីលក្ខណៈជាប្រព័ន្ធ កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨។ បច្ចុប្បន្ន កំពុងរៀបចំឯកសារបិទផ្សាយទិន្នន័យក្បាលដី ដើម្បីឱ្យប្រជាពលរដ្ឋពិនិត្យកែតម្រូវ មុនចេញបណ្ណកម្មសិទ្ធិជូន។

១.៣. ក្រុមប្រជាពលរដ្ឋ ៥៨៥គ្រួសារទទួលបានថវិកា ៣០០០ដុល្លារ និងដីទំហំ២ហិកតាក្នុងមួយគ្រួសារ ស្ថិតនៅឃុំដងពែង និងឃុំជីខលើ ស្រុកស្រែអំបិល និងឃុំកណ្ដោល ស្រុកបូទុមសាគរ។ ក្រុមប្រជាពលរដ្ឋ ៥៨៥គ្រួសារ បានទទួលថវិកា ចាប់ឆ្នោតទទួលដីឡូតិ៍រួចរាល់ហើយ។ បច្ចុប្បន្នកំពុងឈូសឆាយគម្រោងផ្លូវ ដើម្បីឈានទៅធ្វើការវាស់វែង ចេញបណ្ណជូនប្រជាពលរដ្ឋ។

១.៤. បានដោះស្រាយបញ្ចប់ជាមួយប្រជាពលរដ្ឋចំនួន ២៦គ្រួសារ ដែលមានវិវាទជាមួយក្រុមហ៊ុន ហេង ហ៊ុយ អភិវឌ្ឍន៍ ស្ថិតនៅឃុំជីខលើ ស្រុកស្រែអំបិល និងបានចេញបណ្ណជូន ប្រជាពលរដ្ឋចំនួន ១៧គ្រួសារ។ បច្ចុប្បន្ន កំពុងដំណើរការនីតិវិធីចេញបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ០៩ គ្រួសារដែលនៅសល់។

**២. ខេត្តកំពង់ស្ពឺ**

**១០៦.** ក្រុមហ៊ុនចំនួន ៣ មានការពាក់ព័ន្ធនឹងវិវាទដីសម្បទានសេដ្ឋកិច្ចដំណាំអំពៅផលិតស្ករសនាំចេញ រួមមាន ក្រុមហ៊ុនភ្នំពេញស៊ូហ្គើ ក្រុមហ៊ុនកំពង់ស្ពឺស៊ូហ្គើ និងក្រុមហ៊ុនកំពង់ស្ពឺផ្លេនថេសិន។ ក្រុមការងារទទួលបានសលាកបត្រចំនួន ៣៣៤៩សលាកបត្រ។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៨ បានដោះស្រាយបញ្ចប់បានចំនួន ០៩ករណី បានសម្របសម្រួលរួច ចំនួន ១៩៥ករណី និងកំពុងបន្តសិក្សា និងដោះស្រាយលើ សលាកបត្រដែលនៅសេសសល់។

៣. ខេត្តព្រះវិហារ

១០៧. ក្រុមហ៊ុនចំនួន ៥ មានការពាក់ព័ន្ធនឹងវិវាទដីសម្បទានសេដ្ឋកិច្ចដំណាំអំពៅផលិតស្ករសនាំចេញ ប៉ះពាល់ប្រជាពលរដ្ឋចំនួន ២៨៧គ្រួសារ បានមកបំពេញសលាកបត្រ ក្នុងនោះប្រជាពលរដ្ឋចំនួន ៥៧គ្រួសារ បានដោះស្រាយចប់ជាស្ថាពរ និងច្រានចោលប្រជាពលរដ្ឋចំនួន ២៣០គ្រួសារ ផ្សេងទៀត ដោយធ្លាប់បានដោះស្រាយកន្លងមក និងមិនពាក់ព័ន្ធនឹងករណីវិវាទ។ បច្ចុប្បន្ន កំពុងអនុវត្តនីតិវិធីចុះបញ្ជីចេញបណ្ណ ជូនប្រជាពលរដ្ឋ ៥៧គ្រួសារ។

៤. ខេត្តឧត្តរមានជ័យ

១០៨. ក្រុមហ៊ុនចំនួន ៣ ដែលទទួលបាន សម្បទានដីសេដ្ឋកិច្ចដំណាំអំពៅផលិតស្ករសនាំចេញបាន ប្រគល់ដីជូនប្រជាពលរដ្ឋវិញ តាមលិខិតលេខ ២៨៣ សជណ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ការដោះស្រាយបានបញ្ចប់ជាស្ថាពរជូនប្រជាពលរដ្ឋដែលពាក់ព័ន្ធចំនួន ៤១២ គ្រួសារ ដោយផ្តល់ជូនជាដីសម្បទានសង្គមកិច្ចសរុបទំហំ ១០២៨,៣៧ហិកតា ក្នុងនោះទំហំ ៨២៤ ហិកតា សម្រាប់បែងចែកឡូតិ៍ និងទំហំ២០៤,៣៧ហិកតាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ស្ថិតនៅសង្កាត់កូនក្រៀល ក្រុងសំរោង។ ប្រជាពលរដ្ឋចំនួន ៤១២គ្រួសារ បានមកចាប់ឆ្នោតទទួលយកដីរួចរាល់។[21]

III. បញ្ហាប្រឈម

១០៩. ការផ្តល់សេវាសាធារណៈផ្នែករដ្ឋបាល និងផ្នែកយុត្តិធម៌ នៅមិនទាន់ទទួលបានលទ្ធផលល្អប្រសើរជាទីពេញចិត្តទាំងស្រុងរបស់មហាជននៅឡើយ ជាអាទិ៍៖ ការងារកសាងស្ថាប័ន និងក្របខណ្ឌច្បាប់នៅមិនទាន់ឆ្លើយតបតាមតម្រូវការ ហើយការយល់ដឹងក្នុងការអនុវត្តច្បាប់ក៏នៅមិនទាន់មានប្រសិទ្ធភាពពេញលេញទាំងស្រុងដែរ។

១១០. ក្នុងការអនុវត្ត អាជ្ញាធរមានសមត្ថកិច្ច រួមទាំងចៅក្រម និងព្រះរាជអាជ្ញា ជាទូទៅបានផ្អែកទៅលើមូលដ្ឋាននៃច្បាប់ជាតិ នៅក្នុងដំណើរការនីតិវិធី និងការចេញសេចក្តីសម្រេចនានា ដោយពុំទាន់បានប្រើប្រាស់នូវសារជាតុនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិធ្វើជាមូលដ្ឋាននៅឡើយ។ ទោះបីបច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាមានច្បាប់ប្រមាណជា ៥០០ច្បាប់ ដែលភាគច្រើននៃច្បាប់ទាំងនោះបានបញ្ចូលខ្លឹមសារសិទ្ធិមនុស្សស្របតាមរដ្ឋធម្មនុញ្ញកម្ពុជា កតិកាសញ្ញា និងអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាជារដ្ឋភាគីក៏ដោយ ក៏ការអនុវត្តរបស់ភាគីពាក់ព័ន្ធទាំងអស់នៅមានភាពខ្វះចន្លោះខ្លះ ដែលតម្រូវឱ្យមានការកែលម្អបន្ថែមទៀត។ ទន្ទឹមនេះ បទប្បញ្ញត្តិនៃច្បាប់ខ្លះ ក៏កំណត់មិនទាន់បានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយនៅឡើយដែរ ដែលតម្រូវឱ្យមានការធ្វើវិសោធនកម្ម ឬបង្កើតច្បាប់ថ្មីៗបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃសង្គមជាតិ។ [22]

---

[21] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ របាយការណ៍វឌ្ឍនភាពនៃការដោះស្រាយវិវាទពាក់ពន្ធ័នឹងដីសម្បទានសេដ្ឋកិច្ចដំណាំអំពៅផលិតស្ករសនាំចេញរបស់ ឯកឧត្តម ទេព ធន ថ្ងៃទី ១៧ មករា ឆ្នាំ២០១៩

[22] របាយការណ៍ ស្តីពីការត្រួតពិនិត្យឡើងវិញតាមកាលកំណត់ជាសកល ជុំទី៣ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាខែតុលា ឆ្នាំ២០១៨

១១១. ចាប់តាំងពីឆ្នាំ១៩៩៣ មករាជរដ្ឋាភិបាលកម្ពុជា បានផ្តល់លទ្ធភាពយ៉ាងទូលំទូលាយ អនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិជាច្រើន រួមទាំងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ធ្វើសកម្មភាពផ្សព្វផ្សាយ បណ្តុះបណ្តាលអំពីបញ្ហាសិទ្ធិមនុស្សលើគ្រប់ទិដ្ឋភាព ដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ រួមទាំងប្រជាពលរដ្ឋផងដែរ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏រហូតមកដល់ពេលនេះ កម្រិតនៃការយល់ដឹងអំពីសិទ្ធិមនុស្សនៅតែមិនទាន់បានស៊ីជម្រៅនិងច្បាស់លាស់ សម្រាប់ប្រជាពលរដ្ឋក៏ដូចជាតួអង្គផ្សេងៗទៀតដែរ។ ទស្សនៈនៃការយល់ដឹងអំពីសិទ្ធិមនុស្ស ករណីយកិច្ច កាតព្វកិច្ច និងច្បាប់នៅមិនទាន់មានសង្គតិភាពនឹងគ្នារវាងអ្នកទាមទារសិទ្ធិ អ្នកប្រើប្រាស់សិទ្ធិ និងអ្នកការពារសិទ្ធិ។ តួយ៉ាង ការប្រើប្រាស់សេរីភាពនៃការបញ្ចេញមតិ ដែលអ្នកទាមទារ អ្នកប្រើប្រាស់ រួមទាំងអ្នកឃ្លាំមើលសិទ្ធិមនុស្ស នៅមានទស្សនៈពុំទាន់ស្របគ្នាលើការអនុវត្តសិទ្ធិនេះនៅឡើយ ទាំងក្នុងព្រំដែននៃច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។[23]

១១២. ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងផលិតភាពដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជាដែលជាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេស ទាំងក្នុងពេលចំពោះមុខ និងសម្រាប់អនាគតរយៈពេលវែងនៅមានកម្រិតនៅឡើយ។

១១៣. ទោះបីកម្ពុជាសម្រេចបាន ការគ្របដណ្តប់ផ្នែកអប់រំកម្រិតបឋមសិក្សា ប៉ុន្តែនៅមានបញ្ហាប្រឈមផ្នែកលទ្ធផលនៃការរៀនសូត្រ ការបន្តការសិក្សារហូតចប់មធ្យមសិក្សា ដែលជាមូលដ្ឋានសម្រាប់ឈោងចាប់ជំនាញ និងការលើកកម្ពស់គុណភាពឧត្តមសិក្សា ដើម្បីទាញប្រយោជន៍ពីភាពរីកចម្រើននៃបច្ចេកវិទ្យា និងការធ្វើនវានុវត្តលើឧស្សាហកម្ម។[24]

១១៤. ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច នៅមានការយឺតយ៉ាវដោយ មានប្រជាពលរដ្ឋជនជាតិដើមភាគតិចខ្លះ ដែលមានកម្មសិទ្ធិដីឯកជន មានបំណងសុំចូលជាសមាជិកសហគមន៍ ដោយយល់ព្រមលះបង់ដីឯកជនទាំងអស់ មកដាក់បញ្ចូលជាដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ជាមួយនេះ ក៏មានប្រជាពលរដ្ឋ ជនជាតិដើមភាគតិចខ្លះជាសមាជិកសហគមន៍មានបំណងសុំចាកចេញពីសហគមន៍នោះវិញ និងបានទាមទារ ស្នើសុំចុះបញ្ជីដីជាកម្មសិទ្ធិឯកជនលើចំណែកដីដែលខ្លួនបានកាន់កាប់។ សហគមន៍ខ្លះ ទាមទារទំហំដីធំហួសពីតម្រូវការនៃការប្រើប្រាស់របស់ខ្លួន។

## IV. យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

១១៥. រាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តប្តេជ្ញាចិត្តខិតខំប្រឹងប្រែងលើកស្ទួយវិស័យសិទ្ធិមនុស្សឱ្យស្របនឹងធន្ទៈដែលខ្លួនបានទទួលយកលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗចំនួន ៨ ក្នុងចំណោម ៩ និងខ្លឹមសារមាត្រា៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងដាក់ចេញនូវវិធានការនានា

[23] ចំនុចប្រឈមនៃរបាយការណ៍ការតាមការកំណត់នៃស្ថានភាពទូទៅសិទ្ធិមនុស្សនៅកម្ពុជា ២០១៨

[24] រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ ទំព័រ ១៤

ដោយបានកំណត់ជាគោលការណ៍ចម្បងៗ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល អាណត្តិទី៦ នៃរដ្ឋសភាមានដូចខាងក្រោម៖

**១១៦.** ធ្វើទំនើបកម្មស្ថាប័នរដ្ឋ និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន សមធម៌ និងយុត្តិធម៌ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ក្នុងការដឹកនាំ គ្រប់គ្រង និង ចាត់ចែងកិច្ចការប្រទេសជាតិ ជាពិសេសការធានានិរន្តរភាពនៃតួនាទី និងដំណើរការរដ្ឋបាលសាធារណៈ ដោយយកចិត្តទុកដាក់លើផលប្រយោជន៍ប្រជាជនជាស្នូល និងលើការកសាងជាតិ។

**១១៧.** លើកកម្ពស់សេវាយុត្តិធម៌ ដោយបង្កើនប្រសិទ្ធភាពការងាររបស់មន្ត្រីអនុវត្តច្បាប់ ពង្រឹងជំនឿទុកចិត្តពីសាធារណជនលើវិស័យយុត្តិធម៌ និងប្រយុទ្ធប្រឆាំងអំពីបំពានដោយអយុត្តិធម៌នៅក្នុងសង្គម តាមរយៈ

- ការពង្រឹងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ
- ការពង្រឹងភាពស្អាតស្អំ និងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីក្នុងការអនុវត្តច្បាប់
- ការពង្រឹងយន្តការវិន័យការងារ និងការធ្វើទំនើបកម្មរដ្ឋបាលយុត្តិធម៌
- ការលើកកម្ពស់ការផ្តល់សេវាច្បាប់ និង
- ការពង្រឹង និងកែលម្អយន្តការដោះស្រាយវិវាទ ដែលអាចឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់សង្គមប្រកបដោយប្រសិទ្ធភាព។[25]

**១១៨.** បន្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការរៀបចំក្របខណ្ឌច្បាប់ឱ្យមានស្ថិរភាព និងកាន់តែទទួលបាននូវជំនឿទុកចិត្តពីមហាជន ព្រមទាំងពង្រឹងសមត្ថភាព ឯករាជ្យភាព និងភាពមិនលម្អៀងរបស់ស្ថាប័នតុលាការ ដែលជាកត្តាសំខាន់នៃដំណើរការពង្រឹងនីតិរដ្ឋ ការបែងចែកអំណាចដាច់ពីគ្នា ការគោរពសិទ្ធិបុគ្គល និងការធានាភាពយុត្តិធម៌សម្រាប់ប្រជាជនទូទៅ។ បន្តការកសាងច្បាប់ថ្មីៗតាមការចាំបាច់ក្នុងការគ្រប់គ្រងប្រទេស ធានាឱ្យបាននូវការគោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

**១១៩.** ពង្រឹងការអនុវត្តច្បាប់ជាធរមាននានា ឱ្យកាន់តែមានប្រសិទ្ធភាព ដោយបង្កើនការអប់រំផ្សព្វផ្សាយ និងការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ព្រមទាំងធ្វើការផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពស្តីពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ តាមរយៈការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម និងការកែលម្អកម្រិតជីវភាពរស់នៅ រួមទាំងសុខុមាលភាពរបស់ប្រជាជន និងតាមរយៈការអនុវត្តវិធានការចាំបាច់នានាសំដៅលើកកម្ពស់ និងការពារសិទ្ធិសេរីភាពជាមូលដ្ឋាន និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។

**១២០.** ប្តេជ្ញាបន្តអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព នូវគោលនយោបាយអំពីសញ្ជាតិ និងអំពីអន្តោប្រវេសន៍ សំដៅលើកស្ទួយអធិបតេយ្យភាពជាតិ ផលប្រយោជន៍ កិត្តិយស សេចក្តីថ្លៃថ្នូររបស់ប្រជាជាតិ និងភាពសុខដុមរមនាក្នុងសង្គម លើមូលដ្ឋាននៃការគោរពលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ការពង្រឹងនីតិរដ្ឋ ការគោរពច្បាប់ និងលិខិតុបករណ៍អន្តរជាតិនានា។ ធានាឱ្យមានភាពស្មើគ្នាចំពោះមុខច្បាប់ សិទ្ធិសេរីភាព និងករណីយកិច្ចរបស់ប្រជាពលរដ្ឋគ្រប់ៗរូប ដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

---

[25] ស្នូល និង បរិស្ថានគ្រប់ដណ្តប់៖ ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ ទំព័រទី ២៩ នៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤

១២១. បន្តខិតខំស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា តាមរយៈការផ្តល់ និងការកៀគររកថវិកាជួយដល់ អ.វ.ត.ក. ដែលកំពុងតែដំណើរការនាពេលបច្ចុប្បន្ន ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យចន្លោះពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

១២២. បញ្ចូលស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកភេទទី៣ ទៅក្នុងជំពូកក្រុមស្ត្រី និងក្មេងស្រីងាយរងគ្រោះ សម្រាប់ការធ្វើបច្ចុប្បន្នភាពលើការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា និងធ្វើគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ដែលនឹងត្រូវដាក់បញ្ចូលបញ្ហាក្រុមស្ត្រី និងក្មេងងាយរងគ្រោះផងដែរ។

១២៣. បន្តដោះស្រាយ និងលើកកម្ពស់បន្ថែមទៀតនូវសុខុមាលភាពជូនប្រជាជន ដោយបានដាក់ចេញនូវគោលនយោបាយជាក់លាក់ សំដៅជំរុញការអភិវឌ្ឍវិស័យសុខាភិបាល ធានាការផ្តល់សេវាសុខាភិបាលដែលមានគុណភាព ប្រសិទ្ធភាព សមធម៌ និងមាននិរន្តរភាព ដោយផ្តល់អាទិភាពដល់តំបន់ជនបទ តំបន់ដាច់ស្រយាល និងក្រុមជនងាយរងគ្រោះ ជាពិសេស ស្ត្រី កុមារ និងជនចាស់ជរា។ ដើម្បីលើកកម្ពស់ជាប្រចាំនូវស្ថានភាពសុខភាព និងសុខុមាលភាពរបស់ប្រជាជន បង្កលទ្ធភាពឲ្យប្រជាជនគ្រប់រូបចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍជីវភាព សុខុមាលភាពគ្រួសារ និងសេដ្ឋកិច្ចសង្គមរបស់ប្រទេសជាតិ។ ប្រជាជនក្រីក្រត្រូវតែបានទទួលផលប្រយោជន៍ពីប្រព័ន្ធថែទាំសុខភាពសាធារណៈ។

១២៤. បន្តអនុវត្តគោលនយោបាយសមភាពយេនឌ័រ តាមរយៈការបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់វិស័យ និងកម្មវិធីអភិវឌ្ឍន៍នានា។ បន្តបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសង្គមកិច្ច និងយុត្តិធម៌ជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងបន្តបង្កើនកាលានុវត្តភាពដល់ស្ត្រី និងសិស្សស្រីឱ្យទទួលបានការសិក្សារហូតដល់ថ្នាក់ឧត្តម និងក្រោយឧត្តមសិក្សា ព្រមទាំងពង្រីក និងបង្កើនការទទួលសេវាសុខភាព និងអាហារូបត្ថម្ភប្រកបដោយគុណភាព និងប្រសិទ្ធភាព។ បន្តយកចិត្តទុកដាក់បង្កើនសមាមាត្រ និងពង្រឹងសមត្ថភាពស្ត្រីក្នុងវិស័យសាធារណៈនិងវិស័យឯកជន សំដៅពង្រីកលទ្ធភាពឱ្យស្ត្រីបានចូលរួមចំណែកលើកកម្ពស់អភិបាលកិច្ចល្អនៅគ្រប់កម្រិត។ បន្តអនុវត្តវិធានការនានាជាពិសេស ការពង្រឹងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព និងការអនុវត្តផែនការសកម្មភាពជាតិលើកទី២ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី សំដៅកាត់បន្ថយភាពអសកម្ម ពង្រីកវប្បធម៌អហិង្សាដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់សីលធម៌ តម្លៃស្ត្រី និងគ្រួសារខ្មែរ និងកសាងសហគមន៍ប្រកបដោយភាពថ្លៃថ្នូរ គ្រួសារមានសុភមង្គល និងសង្គមជាតិមានសុខដុមរមនា។

១២៥. បន្តសហការជាមួយអង្គការសង្គមស៊ីវិល និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ក្នុងការជំរុញ និងពន្លឿនដំណើរការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឱ្យស្របទៅនឹងគោលការណ៍ទីក្រុងប៉ារីស។

១២៦. បន្តធ្វើកំណែទម្រង់ការបោះឆ្នោត តាមរយៈការពង្រឹងសមត្ថភាពមន្ត្រី ការងារបច្ចេកទេស ការធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា និងទិន្នន័យ ដើម្បីឱ្យការបោះឆ្នោតកាន់តែមានភាពងាយស្រួល មានតម្លាភាព សុចរិតភាព ត្រឹមត្រូវ យុត្តិធម៌ ជាទីទុកចិត្តរបស់ប្រជាពលរដ្ឋកម្ពុជា និងសហគមន៍អន្តរជាតិ។

**១២៧.** បន្តអនុវត្តឱ្យកាន់តែសកម្ម និងស៊ីជម្រៅថែមទៀត នូវកំណែទម្រង់ដីធ្លី ដោយផ្តោតលើការពង្រឹងការគ្រប់គ្រង ការរៀបចំ ការប្រើប្រាស់ និងការបែងចែកដីធ្លី ដើម្បីរួមចំណែកធ្វើឱ្យសម្រេចគោលដៅជាតិក្នុងការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាន និងធនធានធម្មជាតិ កិច្ចការពារជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមស្របតាមសេដ្ឋកិច្ចទីផ្សារសេរី។ បន្តការដោះស្រាយវិវាទដីធ្លីប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន តាមរយៈយន្តការដោះស្រាយវិវាទដីធ្លីទាំងក្នុង និងក្រៅប្រព័ន្ធតុលាការ។ បន្តបង្កើនល្បឿននៃការផ្តល់សម្បទានដីសង្គមកិច្ចជូនប្រជាជន ដែលគ្មានដីសម្រាប់បង្កបង្កើនផលតាមរយៈការប្រើប្រាស់សន្និធិដី ដែលបានមកពីការដកហូតវិញនូវដីសម្បទានសេដ្ឋកិច្ចពីក្រុមហ៊ុនដែលមិនបានគោរពតាមកិច្ចសន្យា និងដីរដ្ឋដែលនៅសល់ក្នុងតំបន់ចុះបញ្ជីនៃបទបញ្ជាលេខ០១ និងដីដែលបានបោសសម្អាតមីនរួច។ បន្តផ្អាកការផ្តល់ដីសម្បទានសេដ្ឋកិច្ច ឬការជួលអចិន្ត្រៃយ៍ ដើម្បីពង្រឹងការគ្រប់គ្រងប្រភេទដីនេះឱ្យបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសន្យា។

**១២៨.** បានដាក់ចេញនូវទិសដៅ និងកម្មវិធីយុទ្ធសាស្ត្រសំខាន់ៗ៖

(១) ដើម្បីជំរុញការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីច្បាប់ និងផ្សព្វផ្សាយដល់សាធារណៈជន(អប់រំសីលធម៌សង្គម) លើកកម្ពស់វប្បធម៌អហិង្សានៅក្នុងសង្គម (២) កែលម្អសេវាសង្គម (ការផ្តល់សេវាចម្រុះ) សេវាសុខាភិបាល(ការធ្វើកោសល្យវិច័យ) និងសេវាផ្នែកច្បាប់ (ការផ្តល់សេវាផ្នែកច្បាប់សម្រាប់ករណីរំលោភ) និងការកែលម្អគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងសិទ្ធិស្ត្រី។ល។

# ឯកសារយោង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា(១៩៩៣)
- ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី(២០១៨)
- ច្បាប់ស្ដីពីរបបសារព័ត៌មាន(១៩៩៥)
- ច្បាប់ស្ដីពីសញ្ជាតិ(២០១៨)
- ច្បាប់អន្តោប្រវេសន៍ ឆ្នាំ១៩៩៤
- ច្បាប់ស្ដីពីការងារ(១៩៩៧) និងវិសោធនកម្មនៃច្បាប់នេះ
- ច្បាប់ស្ដីពីគណបក្សនយោបាយ(១៩៩៧) និងវិសោធនកម្មនៃច្បាប់នេះ
- ច្បាប់ភូមិបាល(២០០១)
- ច្បាប់ស្ដីពីការបោះឆ្នោតឃុំ/សង្កាត់(២០០២)
- ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ(១៩៩៧) និងវិសោធនកម្មឆ្នាំ២០០២
- ច្បាប់ស្ដីពីលក្ខន្តិកៈតំណាងរាស្ត្រ ឆ្នាំ(២០០៦)
- ច្បាប់ស្ដីពីការអប់រំ(២០០៧)
- ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងធ្វើអាជីវកម្មផ្លូវភេទ(២០០៨)
- ក្រមនីតិវិធីរដ្ឋប្បវេណី(២០០៦)
- ក្រមនីតិវិធីព្រហ្មទណ្ឌ(២០០៧)
- ក្រមរដ្ឋប្បវេណី(២០០៧)
- ក្រមព្រហ្មទណ្ឌ(២០០៩)
- ច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (២០១៥)
- ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី
- ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ប្រកាសឱ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ប្រកាសឱ្យប្រើនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្ដីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១
- កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(១៩៩២)
- កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(១៩៩២)
- អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ
- អនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍(១៩៨៣)

- អនុសញ្ញាស្តីពីការប្រឆាំងអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប(១៥ ខែតុលា ឆ្នាំ១៩៩២)
- ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់ និងពេស្យាកម្មកុមារ (២០០២)
- ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការប្រឆាំងទារុណកម្ម(២០០៧)
- ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ(២០១០)
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល នីតិកាលទី៥នៃរដ្ឋសភា
- កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥នៃរដ្ឋសភា
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា
- ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦១៩ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម
- ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៦ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំជាថ្មីនូវគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- អនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីបង្កើតគណៈកម្មាធិការជាតិសម្រាប់ដោះស្រាយបញ្ហាជនអនាថា
- របាយការណ៍បូកសរុបការងារឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨របស់ក្រសួង/ស្ថាប័នពាក់ព័ន្ធ
- ក្រសួងមហាផ្ទៃ សេចក្តីណែនាំលេខ០៤០ សណន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ព្រមទាំងសហគមន៍នានានៅមូលដ្ឋាន
- គោលនយោបាយជាតិរបស់រាជរដ្ឋាភិបាល ស្តីពីការអភិវឌ្ឍសហគមន៍ជនជាតិដើមភាគតិច ដែលបានអនុម័តក្នុងឆ្នាំ២០០៩

................